NaviCare® HMO SNP និង NaviCare® NHC HMO SNP

សេចក្តីសង្ខេបនៃអត្ថប្រយោជន៍

ថ្ងៃទី 1 ខែមករា ឆ្នាំ 2027 - ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2027

តំបន់សេវាកម្ម NaviCare រួមបញ្ចូលទាំងខោនធីក្នុងរដ្ឋ Massachusetts ដូចតទៅ៖

Barnstable, Berkshire, Bristol, Essex, Franklin, Hampden, Hampshire, Middlesex, Norfolk, Plymouth, Suffolk, និង Worcester

fallonhealth

H8928_270014KH_M Approved 08042026

26-679-045KH Rev. 00 6/26

សេចក្តីសង្ខេបនៃអត្ថប្រយោជន៍របស់ NaviCare HMO SNP និង NaviCare NHC HMO SNP

សេចក្តីផ្តើម

ឯកសារនេះគឺជាសេចក្តីសង្ខេបនៃអត្ថប្រយោជន៍ និងសេវាកម្មដែលធានារ៉ាប់រងដោយ NaviCare។ វារួមបញ្ចូលទាំងចម្លើយចំពោះសំណួរដែលគេសួរញឹកញាប់ ព័ត៌មានទំនាក់ទំនងដ៏សំខាន់ ទិដ្ឋភាពទូទៅនៃអត្ថប្រយោជន៍និងសេវាកម្មដែលផ្តល់ជូននិងព័ត៌មានអំពីសិទ្ធិរបស់អ្នកជាសមាជិកនៃគម្រោង NaviCare ។ ពាក្យគន្លឹះ និងនិយមន័យរបស់វាមានតាមលំដាប់អក្ខរក្រមនៅក្នុងជំពូកចុងក្រោយនៃ *សៀវភៅណែនាំសមាជិក* (ពីមុនត្រូវបានគេស្គាល់ថាជា *ភស្តុតាងនៃការធានារ៉ាប់រង ឬ EOC*)។

តារាងមាតិកា

A. សេចក្តីប្រកាសបដិសេធមិនទទួលខុសត្រូវ 3

B. សំណួរដែលគេសួរញឹកញាប់(FAQ) 8

C. បញ្ជីសេវាដែលមានការគ្របដណ្តប់ 13

D. អត្ថប្រយោជន៍ដែលត្រូវបានគ្របដណ្តប់នៅក្រៅ NaviCare 26

E. សេវាកម្មដែល NaviCare, Medicare និង MassHealth (Medicaid) មិនធានារ៉ាប់រង 26

F. សិទ្ធិរបស់អ្នកជាសមាជិកនៃគម្រោងនេះ 27

G. របៀបនៃការដាក់ពាក្យបណ្តឹងឬប្តឹងឧទ្ធរណ៍លើការបដិសេធសេវាកម្ម 29

H. តើអ្នកត្រូវធ្វើអ្វីប្រសិនបើអ្នកសង្ស័យថាមានការក្លែងបន្លំ 29

I. អ្វីដែលត្រូវធ្វើ ប្រសិនបើអ្នកចង់បានជំនួយឯករាជ្យជាមួយពាក្យបណ្តឹង ឬកង្វល់ 29

សេចក្តីសង្ខេបនៃអត្ថប្រយោជន៍របស់ NaviCare HMO SNP និង NaviCare NHC HMO SNP

A. សេចក្តីប្រកាសបដិសេធមិនទទួលខុសត្រូវ

នេះគឺជាសេចក្តីសង្ខេបនៃសេវាថែទាំសុខភាពដែលត្រូវបានធានារ៉ាប់រងដោយកម្មវិធី NaviCare របស់ Fallon Health សម្រាប់ឆ្នាំ 2027។ នេះគ្រាន់តែជាសេចក្តីសង្ខេបប៉ុណ្ណោះ។ សូមអាន *សៀវភៅណែនាំសមាជិក* សម្រាប់បញ្ជីពេញលេញនៃអត្ថប្រយោជន៍។
ប្រសិនបើអ្នកមិនមាន *សៀវភៅណែនាំសមាជិក* ទេសូមទូរសព្ទទៅផ្នែកប្រើសេវាអ្នកចុះឈ្មោះ NaviCare តាមរយៈលេខដែលបានរាយនៅខាងក្រោមទំព័រនេះ ដើម្បីទទួលបានមួយ។ ឬអ្នកអាចចូលមើលគេហទំព័ររបស់យើង fallonhealth.org/navicare ហើយចុចលើបដាដែលមានចំណងជើងថា “អត្ថប្រយោជន៍ និងសេវាកម្ម” ។

- NaviCare HMO SNP/NaviCare NHC HMO SNP គឺជាគម្រោង Dual Special Needs Plan (D-SNP) ដែលមានកិច្ចសន្យាជាមួយ Medicare និងកិច្ចសន្យាជាមួយកម្មវិធី Commonwealth of Massachusetts MassHealth (Medicaid)។
  ការចុះឈ្មោះក្នុងគម្រោងអាស្រ័យលើការបន្តកិច្ចសន្យារបស់គម្រោងជាមួយ Medicare។
  គម្រោងនេះគឺជាកម្មវិធីស្ម័គ្រចិត្តដែលមានសម្រាប់អ្នកដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ MassHealth Standard និង Original Medicare ហើយមិនមានការធានារ៉ាប់រងសុខភាពដ៏ទូលំទូលាយផ្សេងទៀតទេ លើកលែងតែ Medicare។
- សម្រាប់ព័ត៌មានបន្ថែមអំពី Medicare អ្នកអាចអានសៀវភៅណែនាំអំពី Medicare និងអ្នក។ សៀវភៅនេះមានសេចក្តីសង្ខេបអំពីអត្ថប្រយោជន៍ Medicare សិទ្ធិ និងកិច្ចការពារ និងចម្លើយចំពោះសំណួរដែលគេសួរញឹកញាប់អំពី Medicare។ អ្នកអាចទទួលបានវាពីគេហទំព័រ Medicare (www.medicare.gov) ឬដោយទូរសព្ទទៅ 1-800-MEDICARE (1-800-633-4227) បាន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។ អ្នកប្រើ TTY គួរទូរសព្ទទៅកាន់លេខ 1-877-486-2048 ។
- សម្រាប់ព័ត៌មានបន្ថែមអំពី MassHealth (Medicaid)
  អ្នកអាចទាក់ទងការិយាល័យមន្ត្រីបណ្តឹងសាធារណៈតាមរយៈទូរសព្ទលេខ 1-855-781-9898 (ឥតគិតថ្លៃ)។
  អ្នកប្រើទូរសព្ទវីដេអូ (VP) អាចទូរសព្ទទៅលេខ 339-224-6831 ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង 9 ព្រឹក ដល់ម៉ោង 4 ល្ងាច។
- ប្រសិនបើអ្នកត្រូវការឯកសារនេះដោយឥតគិតថ្លៃក្នុងទម្រង់ផ្សេងទៀត ដូចជាក្នុងទម្រង់ជាអក្សរពុម្ពធំ អក្សរស្ទាបសម្រាប់អ្នកពិការភ្នែក ឬជាសំឡេង។ សូមទូរសព្ទទៅលេខ 1-877-700-6996 (TTY 711) ពីម៉ោង 8 ព្រឹក ដល់ម៉ោង 8 យប់ ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ (7 ថ្ងៃក្នុងមួយសប្តាហ៍ ពីថ្ងៃទី 1 ខែតុលា ដល់ថ្ងៃទី 31 ខែមីនា)។ ការទាក់ទងតាមទូរស័ព្ទនេះគឺពុំគិតថ្លៃឡើយ។
- ឯកសារនេះអាចរកបានដោយឥតគិតថ្លៃជាភាសាខ្មែរ ភាសាអេស្ប៉ាញ និងភាសាវៀតណាម ហើយភាសាផ្សេងទៀតអាចរកបានដោយឥតគិតថ្លៃតាមការស្នើសុំ។
- ភាសាចំណូលចិត្តរបស់អ្នក ទាំងការសរសេរ និងការនិយាយ ឬសំណើសម្រាប់ព័ត៌មានជាទម្រង់ជំនួសត្រូវបានស្នើសុំដោយគម្រោងនៅលើទម្រង់ចុះឈ្មោះនីមួយៗ។ ចំណូលចិត្តភាសារបស់អ្នកនឹងត្រូវបានចាប់យក និងរក្សាទុកនៅក្នុងប្រព័ន្ធប្រតិបត្តិការកណ្តាលរបស់គម្រោងជាសំណើអចិន្ត្រៃយ៍សម្រាប់ការផ្ញើ និងការទំនាក់ទំនងនាពេលអនាគត។

ការបដិសេធមិនទទួលខុសត្រូវ បន្ត

- នៅពេលដែលបានចុះឈ្មោះ អ្នកអាចផ្លាស់ប្តូរភាសា
ឬទម្រង់ទំនាក់ទំនងដែលអ្នកពេញចិត្តដោយការជូនដំណឹងដល់សមាជិកនៃក្រុមថែទាំសុខភាពរបស់អ្នក
ឬដោយការទូរសព្ទទៅផ្នែកបម្រើសេវាអ្នកចុះឈ្មោះរបស់ NaviCare
តាមរយៈលេខដែលបានរាយនៅខាងក្រោមទំព័រនេះ។
- ការយល់ដឹងអំពីការស្តារអចលនទ្រព្យ៖ MassHealth (Medicaid)
ត្រូវបានតម្រូវដោយច្បាប់សហព័ន្ធដើម្បីទាញយកប្រាក់ពីអចលនទ្រព្យរបស់សមាជិក MassHealth (Medicaid)
ជាក់លាក់ដែលមានអាយុចាប់ពី 55 ឆ្នាំឡើងទៅ ហើយដែលមានអាយុប៉ុន្មានក៏ដោយ
ដែលកំពុងទទួលបានការថែទាំរយៈពេលវែងនៅក្នុងមណ្ឌលថែទាំមនុស្សចាស់ ឬស្ថាប័នវេជ្ជសាស្ត្រផ្សេងទៀត។
សម្រាប់ព័ត៌មានបន្ថែមអំពីការស្តារអចលនទ្រព្យរបស់ MassHealth (Medicaid) សូមចូលមើល
www.mass.gov/estaterecovery។

Notice of availability of language assistance services and auxiliary aids and services

You can get this document for free in other formats, such as large print, braille, or audio. Call 1-877-700-6996 (TTY 711) 8 a.m.–8 p.m., Monday–Friday (7 days a week, Oct. 1-March 31). The call is free.

English: We have free interpreter services to answer any questions you may have about our health or drug plan. To get an interpreter, just call us at 1-877-700-6996. Someone who speaks English can help you. The call is free. We also provide free auxiliary aids and services, such as large print, braille, or audio. Just call us at the number above to make this request.

Spanish: Contamos con servicios de intérprete gratuitos para responder cualquier pregunta que tenga sobre nuestro plan de salud o medicamentos. Para obtener un intérprete, solo llámenos al 1-877-700-6996. Alguien que habla español podrá ayudarle. La llamada es gratuita. También ofrecemos ayudas y servicios auxiliares gratuitos, como impresión en letra grande, braille o audio. Solo llámenos al número mencionado arriba para hacer esta solicitud.

Chinese: 我們提供免費口譯服務，以解答您有關我們的健康或藥物計劃的任何問題。如需口譯服務，請撥打 1-877-700-6996。會有說中文的人為您提供幫助。此為免付費電話。我們也提供免費的輔助工具和服務，例如大號字體印刷版、盲文或音訊。請撥打上述電話向我們提出請求。

French: Nous disposons de services d'interprétation gratuits pour répondre à toutes les questions que vous pourriez avoir sur notre régime de santé ou d'assurance médicaments. Pour obtenir un interprète, il vous suffit de nous appeler au 1-877-700-6996. Une personne parlant français pourra vous aider. L'appel est gratuit. Nous fournissons également gratuitement des aides et des services auxiliaires, tels que des documents en gros caractères, en braille ou audio. Il vous suffit de nous appeler au numéro ci-dessus pour en faire la demande.

Vietnamese: Chúng tôi cung cấp dịch vụ thông dịch miễn phí để giải đáp mọi thắc mắc liên quan đến chương trình bảo hiểm sức khỏe hoặc chương trình thuốc của chúng tôi. Để yêu cầu chúng tôi bố trí thông dịch viên, vui lòng gọi điện đến số 1-877-700-6996. Một nhân viên nói tiếng Việt sẽ hỗ trợ quý vị. Cuộc gọi này hoàn toàn miễn phí. Chúng tôi cũng cung cấp các công cụ và dịch vụ hỗ trợ miễn phí, chẳng hạn như bản in khổ chữ lớn, chữ nổi Braille hoặc băng thu âm. Quý vị chỉ cần gọi cho chúng tôi theo số điện thoại bên trên để yêu cầu các dịch vụ này.

Korean: 저희는 건강 플랜 또는 의약품 플랜에 관한 질문에 답변해 드릴 무료 통역 서비스를 제공합니다. 통역사를 이용하시려면 1-877-700-6996로 전화해 주십시오. 한국어를 구사하는 직원이 도와드릴 수 있습니다. 통화는 무료입니다. 또한 큰 활자, 점자 또는 오디오와 같은 무료 보조 지원과 서비스도 제공합니다. 이러한 요청을 하시려면 위의 번호로 전화해 주십시오.

Russian: Мы можем предоставить вам бесплатные услуги переводчика, чтобы вы могли получить ответы на все ваши вопросы о нашем плане медицинского обслуживания и обеспечения лекарственными препаратами. Чтобы запросить услуги переводчика, просто позвоните по номеру 1-877-700-6996. Сотрудник, владеющий русским языком, сможет вам помочь. Звонок бесплатный. Мы также предлагаем бесплатные вспомогательные средства и услуги, например материалы, напечатанные крупным шрифтом, шрифтом Брайля или в виде аудиозаписи. Просто позвоните нам по

вышеуказанному номеру, чтобы сделать соответствующий запрос.

Arabic:

لدينا خدمات مترجم فوري مجانية للإجابة على أي أسئلة التي قد تكون لديك حول خطتنا للرعاية الصحية أو خطة الأدوية الخاصة بنا. للحصول على مترجم فوري، فقط اتصل بنا على الرقم 1-800-325-5669. يمكن لشخص يتكلم اللغة الإنجليزية أن يساعدك. إن المكالمة مجانية. نحن نقدم أيضًا مساعدات وخدمات مساعدة مجانية، مثل طباعة بأحرف كبيرة، أو بطريقة برايل، أو ملفات صوتية. فقط اتصل بنا على الرقم المذكور أعلاه لتقديم هذا الطلب.

Hindi: हमारे स्वास्थ्य या दवा योजना के बारे में आपके किसी भी प्रश्न का उत्तर देने के लिए हमारे पास निःशुल्क दुभाषिया सेवाएँ हैं। दुभाषिया पाने के लिए बस हमें 1-877-700-6996 पर कॉल करें। कोई हिन्दी बोलने वाला व्यक्ति आपकी मदद कर सकता है। कॉल निःशुल्क है। हम बड़े प्रिंट, ब्रेल या ऑडियो जैसी निःशुल्क सहायक सामग्री और सेवाएं भी प्रदान करते हैं। इस अनुरोध के लिए बस हमें ऊपर दिए गए नंबर पर कॉल करें।

Italian: Disponiamo di servizi gratuiti di interpretariato per rispondere a eventuali domande sul nostro piano sanitario o farmaceutico. Per chiedere un interprete basta chiamarci al numero 1-877-700-6996. La assisterà un operatore che parla italiano. La chiamata è gratuita. Forniamo inoltre servizi e supporti ausiliari gratuiti, come ad esempio stampa in caratteri grandi, braille o audio. Per questa richiesta basta chiamarci al numero sopra indicato.

Portuguese: Temos serviços de intérprete gratuitos para responder a quaisquer perguntas que possa ter sobre o nosso plano de saúde ou medicamentos. Para obter um intérprete, ligue para 1-877-700-6996. Alguém que fala português poderá prestar assistência. A chamada é gratuita. Também fornecemos recursos e serviços auxiliares gratuitos, como impressão em letras grandes, braile ou áudio. Basta ligar para o número acima e fazer tal solicitação.

Haitian Creole: Nou gen sèvis entèprèt gratis pou reponn nenpòt kesyon ou ka genyen sou plan sante oswa medikaman nou an. Pou jwenn yon entèprèt, jis rele nou nan 1-877-700-6996. Yon moun ki pale kreyòl ka ede w. Apèl la gratis. Nou bay èd ak sèvis oksilyè gratis tou, tankou gwo lèt, bray oswa odyo. Jis rele nou nan nimewo ki anwo a pou fè demann sa a.

Polish: Oferujemy bezpłatne usługi tłumaczeniowe, aby odpowiedzieć na wszystkie Państwa pytania dotyczące planu ubezpieczenia zdrowotnego lub refundacji leków. Aby skorzystać z usług tłumacza, należy zadzwonić pod numer 1-877-700-6996. Osoba mówiąca po polsku udzieli Państwu pomocy. Połączenie jest bezpłatne. Zapewniamy również wsparcie i usługi pomocnicze, takie jak materiały pisane dużym drukiem, alfabetem Braille'a lub nagrania głosowe. Aby o nie poprosić, wystarczy zadzwonić pod podany powyżej numer telefonu.

Khmer: យើងមានសេវាកម្មអ្នកបកប្រែផ្តាល់មាត់តតគិតថ្លៃដើម្បីឆ្លើយសំណួរណាមួយ ដែលអ្នកអាចមានអំពីគម្រោងសុខភាព ឬគម្រោងឱសថរបស់អ្នក។ ដើម្បីទទួលបានអ្នកបកប្រែផ្តាល់មាត់ម្នាក់ សូមទូរសព្ទមកយើងតាមលេខ 1-877-700-6996។ នរណាម្នាក់ដែលនិយាយ ភាសាអង់គ្លេស អាចជួយអ្នកបាន។ ការទាក់ទងតាមទូរសព្ទនេះគឺពុំគិតថ្លៃឡើយ។ យើងក៏ផ្តល់ជំនួយបន្ថែម និងសេវាកម្មជំនួយដោយតតគិតថ្លៃផងដែរ ដូចជាអក្សរពុម្ពធំ អក្សរស្ទាប ឬសំឡេង។ ក្រាន់តែទូរសព្ទមកយើងខ្ញុំតាមលេខខាងលើដើម្បីធ្វើការស្នើសុំនេះ។

Greek: Διαθέτουμε δωρεάν υπηρεσίες διερμηνείας για να απαντάμε σε οποιεσδήποτε ερωτήσεις μπορεί να έχετε σχετικά με το πρόγραμμα ιατρικής ή φαρμακευτικής περίθαλψης που παρέχουμε. Για να βρείτε διερμηνέα, απλώς καλέστε μας στον αριθμό 1-877-700-6996. Κάποιος που μιλά αγγλικά μπορεί να σας βοηθήσει. Η κλήση είναι χωρίς χρέωση. Επίσης, παρέχουμε δωρεάν βοηθήματα και βοηθητικές υπηρεσίες, όπως μεγάλη γραμματοσειρά, μπράιγ ή ηχητική μορφή. Απλώς καλέστε μας στον παραπάνω αριθμό για να υποβάλετε αυτό το αίτημα.

សេចក្តីសង្ខេបនៃអត្ថប្រយោជន៍របស់ NaviCare HMO SNP និង NaviCare NHC HMO SNP

Gujarati: અમારી આરોગ્ય અથવા દવા યોજના વિશે તમને હોય શકે તેવા કોઈપણ પ્રશ્નોના જવાબ આપવા માટે અમારી પાસે મફત દુભાષિયા સેવા છે. દુભાષિયા સેવા મેળવવા માટે, અમને 1-877-700-6996 પર કૉલ કરો. ગુજરાતી બોલતી વ્યક્તિ તમને મદદ કરી શકે છે. કૉલ મફત છે. અમે મોટા પ્રિન્ટ, બ્રેઇલ અથવા ઑડિઓ જેવી મફત વધારાની સહાય અને સેવાઓ પણ પ્રદાન કરીએ છીએ. આ વિનંતી કરવા માટે અમને ફક્ત ઉપરના નંબર પર કૉલ કરો.

Laotian: ພວກເຮົາມີການບໍລິການນາຍແປພາສາຟຣີ ເພື່ອຕອບທຸກຄຳຖາມທີ່ທ່ານອາດຈະມີກ່ຽວກັບແຜນປະກັນສຸຂະພາບ ຫຼື ແຜນປະກັນຢາຂອງພວກເຮົາ ເພື່ອຂໍນາຍແປພາສາ, ພຽງແຕ່ໂທຫາພວກເຮົາທີ່ເບີ 1-877-700-6996.
ຈະມີຄົນທີ່ສາມາດເວົ້າພາສາລາວມາຊ່ວຍທ່ານ. ການໂທແມ່ນບໍ່ເສຍຄ່າ. ນອກຈາກນີ້, ພວກເຮົາຍັງໃຫ້ການຊ່ວຍເຫຼືອ ແລະ ການບໍລິການເສີມແບບບໍ່ເສຍຄ່າອີກດ້ວຍ ເຊັ່ນ: ການພິມເປັນຕົວໃຫຍ່, ຕົວອັກສອນນູນ ຫຼື ສຽງບັນທຶກ.
ພຽງແຕ່ໂທຫາພວກເຮົາຕາມເບີຂ້າງເທິງ ເພື່ອຮ້ອງຂໍສິ່ງນີ້.

H8928_250863KH_C Approved 04092025

25-676-012KH Rev. 00 3/25

B. សំណួរដែលគេសួរញឹកញាប់(FAQ)

តារាងខាងក្រោមរាយបញ្ជីសំណួរដែលគេសួរញឹកញាប់។

សំណួរដែលគេសួរញឹកញាប់	ចម្លើយ
តើគម្រោង Senior Care Options (SCO) គឺជាអ្វី?	Senior Care Options (SCO) គឺជាកម្មវិធីថែទាំដែលមានការគ្រប់គ្រងដែលរួមបញ្ចូលគ្នានូវអត្ថប្រយោជន៍ MassHealth (Medicaid) និង Medicare ទៅក្នុងគម្រោងតែមួយជាមួយនឹងក្រុមថែទាំមួយសម្រាប់មនុស្សដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ។ ជាមួយ SCO អ្នកនឹងមានអ្នកសម្របសម្រួលដើម្បីជួយអ្នកគ្រប់គ្រងការថែទាំរបស់អ្នក រក្សាសុខភាព និងទទួលបានសេវាកម្មដែលអ្នកត្រូវការ។ មនុស្សដែលមានសិទ្ធិទទួលបាន SCO ជាទូទៅមិនមានថ្លៃធានារ៉ាប់រងប្រចាំខែ ឬមានទាប គ្មានការបង់ប្រាក់រួម និងថ្លៃចំណាយចេញពីហោប៉ៅតិចតួចសម្រាប់សេវាកម្មដែលត្រូវបានធានារ៉ាប់រងភាគច្រើន។ SCO រ៉ាប់រងលើឱសថវេជ្ជសាស្ត្រ សុខភាពអាកប្បកិរិយា និងឱសថតាមវេជ្ជបញ្ជា បូករួមទាំងសេវាគាំទ្រមនុស្សចាស់ឯកទេស។ NaviCare គឺជាគម្រោង SCO ដែលផ្តល់អត្ថប្រយោជន៍នៃ MassHealth (Medicaid) និង Medicare រួមទាំងអត្ថប្រយោជន៍ឱសថដែលត្រូវបានធានារ៉ាប់រងដល់អ្នកចុះឈ្មោះក្នុងកម្មវិធី SCO។ អ្នកចុះឈ្មោះក្នុងកម្មវិធី NaviCare ត្រូវតែមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ មាន MassHealth Standard និង Medicare ផ្នែក A និង B ហើយរស់នៅក្នុងតំបន់សេវាកម្ម។
តើខ្ញុំនឹងទទួលបានអត្ថប្រយោជន៍ Medicare និង MassHealth (Medicaid) ដូចគ្នានៅក្នុង NaviCare ដែលខ្ញុំទទួលបានឥឡូវនេះដែរឬទេ?	អ្នកនឹងទទួលបានអត្ថប្រយោជន៍ Medicare និង MassHealth (Medicaid) ដែលត្រូវបានធានារ៉ាប់រងភាគច្រើនរបស់អ្នកដោយផ្ទាល់ពី NaviCare។ អ្នកនឹងធ្វើការជាមួយក្រុមអ្នកផ្តល់សេវាដែលនឹងជួយកំណត់ថាតើសេវាកម្មបែបណាដែលល្អបំផុតសមនឹងតម្រូវការផ្សេងៗរបស់អ្នក។ នេះមានន័យថាសេវាកម្មមួយចំនួនដែលអ្នកទទួលបានឥឡូវនេះអាចផ្លាស់ប្តូរដោយផ្អែកលើតម្រូវការរបស់អ្នក និងការវាយតម្លៃរបស់វេជ្ជបណ្ឌិត និងក្រុមថែទាំរបស់អ្នក។ អ្នកក៏អាចទទួលបានអត្ថប្រយោជន៍ផ្សេងទៀតក្រៅពីគម្រោងសុខភាពរបស់អ្នកតាមរបៀបដែលអ្នកទទួលបានឥឡូវនេះ ដោយផ្ទាល់ពីទីភ្នាក់ងាររដ្ឋដូចជាក្រសួងសុខភាពផ្លូវចិត្ត ឬក្រសួងសេវាកម្មផ្នែកអភិវឌ្ឍន៍។ នៅពេលអ្នកចុះឈ្មោះចូលក្នុង NaviCare អ្នកនិងក្រុមការងារថែទាំសុខភាពរបស់អ្នកនឹងធ្វើការរួមគ្នាដើម្បីអភិវឌ្ឍផែនការថែទាំមួយដើម្បីដោះស្រាយ តម្រូវការសុខភាព និងការគាំទ្ររបស់អ្នក ដោយការឆ្លុះបញ្ចាំងអំពី ចំណង់ចំណូលចិត្តនិងគោលដៅផ្ទាល់ខ្លួនរបស់អ្នក។ ប្រសិនបើអ្នកកំពុងប្រើឱសថ Medicare ផ្នែក D ណាមួយដែល NaviCare ជាធម្មតាមិនធានារ៉ាប់រង នោះអ្នកអាចទទួលបានការផ្តត់ផ្តង់បណ្តោះអាសន្ន ហើយយើងនឹងជួយអ្នកក្នុងការផ្លាស់ប្តូរទៅឱសថផ្សេងទៀត ឬទទួលបានការលើកលែងដើម្បីឱ្យ NaviCare ធានារ៉ាប់រងលើឱសថរបស់អ្នក ប្រសិនបើមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ។ សម្រាប់សេវាកម្មផ្សេងទៀតទាំងអស់ អ្នកអាចបន្តជួបវេជ្ជបណ្ឌិតរបស់អ្នក និងទទួលបានសេវាកម្មបច្ចុប្បន្នរបស់អ្នករយៈពេល 90 ថ្ងៃ ឬរហូតដល់ការវាយតម្លៃ និងគម្រោងថែទាំរបស់អ្នកត្រូវបានបញ្ចប់។ សម្រាប់ព័ត៌មានបន្ថែម សូមទូរសព្ទទៅផ្នែកសេវាបម្រើអ្នកចុះឈ្មោះតាមរយៈលេខដែលបានរាយនៅផ្នែកខាងក្រោមនៃទំព័រនេះ។

សំណួរដែលគេសួរញឹកញាប់ (FAQ) *បន្ត*

សំណួរដែលគេច្រើនសួរ	ចម្លើយ
តើខ្ញុំអាចប្រើវេជ្ជបណ្ឌិតដូចគ្នាដែលខ្ញុំប្រើឥឡូវនេះដែរឬទេ?	ករណីដូច្នេះមានជាញឹកញាប់។ ប្រសិនបើអ្នកផ្តល់សេវា (រួមទាំងវេជ្ជបណ្ឌិត មន្ទីរពេទ្យ អ្នកព្យាបាលរោគ ឱសថស្ថាននិងអ្នកផ្តល់សេវាថែទាំសុខភាពផ្សេងទៀត) ធ្វើការជាមួយ NaviCare ហើយមានកិច្ចសន្យាជាមួយយើង អ្នកអាចបន្តទៅរកពួកគេ។ • អ្នកផ្តល់សេវាដែលមានកិច្ចព្រមព្រៀងជាមួយយើងគឺ "នៅក្នុងបណ្តាញ"។ អ្នកផ្តល់សេវាក្នុងបណ្តាញចូលរួមក្នុងគម្រោងរបស់យើង។ នោះមានន័យថាពួកគេទទួលយកសមាជិកគម្រោងរបស់យើងនិងផ្តល់សេវាដែលគម្រោងរបស់យើងគ្របដណ្តប់។ អ្នកត្រូវតែប្រើអ្នកផ្តល់សេវានៅក្នុងបណ្តាញ NaviCare ។ ប្រសិនបើអ្នកប្រើអ្នកផ្តល់សេវា ឬឱសថស្ថានដែលមិនស្ថិតនៅក្នុងបណ្តាញរបស់យើង នោះគម្រោងអាចនឹងមិនបង់ប្រាក់សម្រាប់សេវាកម្ម ឬឱសថទាំងនេះទេ។ • ប្រសិនបើអ្នកត្រូវការការព្យាបាលបន្ទាន់ឬសង្គ្រោះបន្ទាន់ឬសេវាលាងសម្អាតខាងក្រៅតំបន់សេវា អ្នកអាចប្រើអ្នកផ្តល់សេវាក្រៅពីគម្រោងរបស់ NaviCare ។ សេវាថែទាំបន្ទាន់ និងសង្គ្រោះបន្ទាន់ត្រូវបានធានារ៉ាប់រងនៅទូទាំងពិភពលោក។ សេវាលាងឈាមនៅក្រៅតំបន់ត្រូវបានរ៉ាប់រងតែនៅឯមណ្ឌលលាងឈាមដែលមានការបញ្ជាក់ពី Medicare នៅទីកន្លែងណាមួយនៅក្នុងសហរដ្ឋអាមេរិក ឬដែនដីរបស់ខ្លួន។ • ប្រសិនបើអ្នកមានអ្នកផ្តល់សេវាដែលអ្នកកំពុងទៅរក ហើយពួកគេមិនស្ថិតនៅក្នុងបណ្តាញរបស់យើងទេ អ្នកអាចបន្តជួបពួកគេសម្រាប់រយៈពេល 90 ថ្ងៃដំបូងនៃសមាជិកភាព NaviCare របស់អ្នក ឬរហូតដល់អ្នកត្រូវបានវាយតម្លៃដោយក្រុមថែទាំរបស់អ្នក ហើយគម្រោងថែទាំរបស់អ្នកត្រូវបានអនុវត្ត ដោយគិតយកមួយណាដែលកើតមានមុន។ ដើម្បីស្វែងយល់ថាតើអ្នកផ្តល់សេវារបស់អ្នកស្ថិតនៅក្នុងបណ្តាញរបស់គម្រោងដែរឬទេ សូមទូរសព្ទទៅផ្នែកសេវាបម្រើអ្នកចុះឈ្មោះតាមរយៈលេខដែលបានរាយនៅផ្នែកខាងក្រោមនៃទំព័រនេះ ឬអានបញ្ជីរាយឈ្មោះអ្នកផ្តល់សេវា និងឱសថស្ថានរបស់ NaviCare នៅលើគេហទំព័ររបស់គម្រោងនៅ fallonhealth.org/navicare។ ប្រសិនបើ NaviCare ថ្មីសម្រាប់អ្នក យើងនឹងធ្វើការជាមួយអ្នកដើម្បីបង្កើតគម្រោងថែទាំដើម្បីដោះស្រាយតម្រូវការរបស់អ្នក។
តើអ្នកស្វែងរកសេវារបស់ NaviCare គឺជាអ្វី?	អ្នកសម្របសម្រួលការថែទាំ NaviCare គឺជាមនុស្សសំខាន់ម្នាក់សម្រាប់អ្នកដើម្បីទាក់ទង។ បុគ្គលនេះជួយគ្រប់គ្រងរាល់អ្នកផ្តល់សេវានិងសេវាកម្មរបស់អ្នកទាំងអស់ហើយធ្វើឱ្យប្រាកដថាអ្នកទទួលបាននូវអ្វីដែលអ្នកត្រូវការ។

សំណួរដែលគេសួរញឹកញាប់ (FAQ) *បន្ត*

សំណួរដែលគេច្រើនសួរ	ចម្លើយ
តើសេវាកម្មនិងការគាំទ្ររយៈពេលយូរ (LTSS) គឺជាអ្វី?	សេវាកម្ម និងការគាំទ្ររយៈពេលវែង ជាជំនួយសម្រាប់មនុស្សដែលត្រូវការជំនួយក្នុងការធ្វើកិច្ចការប្រចាំថ្ងៃដូចជាការងូតទឹក ការប្រើប្រាស់បង្គន់ ការស្លៀកពាក់ ការធ្វើម្ហូប និងការលេបថ្នាំ។ សេវាកម្មភាគច្រើនត្រូវបានផ្តល់ជូនតាមផ្ទះ ឬនៅតាមសហគមន៍របស់អ្នក ប៉ុន្តែអាចផ្តល់ជូននៅតាមគិលានុប្បដ្ឋានតាមផ្ទះ ឬមន្ទីរពេទ្យ។ ក្នុងករណីមួយចំនួន ខោនធី ឬទីភ្នាក់ងារផ្សេងទៀតអាចគ្រប់គ្រងសេវាកម្មទាំងនេះ ហើយអ្នកស្វែងរកសេវា ឬក្រុមថែទាំរបស់អ្នកនឹងធ្វើការជាមួយទីភ្នាក់ងារនោះ។
ប្រសិនបើខ្ញុំត្រូវការសេវាមួយ ប៉ុន្តែគ្មាននរណាម្នាក់នៅក្នុងបណ្តាញរបស់ NaviCare អាចផ្តល់វាបាន តើមានអ្វីកើតឡើង?	សេវាកម្មភាគច្រើនផ្តល់ជូនដោយអ្នកផ្តល់សេវាក្នុងបណ្តាញរបស់យើង។ ប្រសិនបើអ្នកត្រូវការសេវាកម្មដែលមិនអាចផ្តល់ជូននៅក្នុងបណ្តាញរបស់យើង NaviCare នឹងបង់ថ្លៃអ្នកផ្តល់សេវាក្រៅបណ្តាញ។
តើ NaviCare មាននៅឯណា?	តំបន់សេវាកម្មសម្រាប់គម្រោងនេះរួមមាន៖ ខោនធី Barnstable, Berkshire, Bristol, Essex, Franklin, Hampden, Hampshire, Middlesex, Norfolk, Plymouth, Suffolk និង Worcester ក្នុងរដ្ឋ Massachusetts។ អ្នកត្រូវតែរស់នៅ តំបន់នេះ ដើម្បីចូលរួមជាមួយគំរោង។

សំណួរដែលគេសួរញឹកញាប់ (FAQ) *បន្ត*

សំណួរដែលគេច្រើនសួរ	ចម្លើយ
តើការស្នើសុំការអនុញ្ញាតជាមុនគឺជាអ្វី?	ការអនុញ្ញាតជាមុនមានន័យថាការយល់ព្រមពី NaviCare ដើម្បីស្វែងរកសេវាកម្ម នៅខាងក្រៅបណ្តាញរបស់យើងឬដើម្បីទទួលបានសេវាកម្មដែលមិនត្រូវបានធានារ៉ាប់រងជាប្រចាំដោយបណ្តាញរបស់យើងមុនពេលអ្នកទទួលបានសេវាកម្ម។ NaviCare មិនអាចគ្របដណ្តប់សេវា នីតិវិធីព្យាបាល សម្ភារៈឬឱសថបានទេប្រសិនបើអ្នកមិនទទួលបានការយល់ព្រមជាមុន។ ប្រសិនបើអ្នកត្រូវការការថែទាំបន្ទាន់ ឬសង្គ្រោះបន្ទាន់ ឬសេវាកម្មលាងឈាមក្រៅតំបន់ អ្នកមិនចាំបាច់ទទួលបានការអនុញ្ញាតជាមុនទេ។ NaviCare អាចផ្តល់ឱ្យអ្នក ឬអ្នកផ្តល់សេវារបស់អ្នកនូវបញ្ជីសេវាកម្ម ឬនីតិវិធីដែលតម្រូវឱ្យអ្នកទទួលបានការអនុញ្ញាតជាមុនពី NaviCare មុនពេលសេវាកម្មត្រូវបានផ្តល់ជូន។ សូមមើលជំពូកទី 3 នៃ *សៀវភៅណែនាំសមាជិក* ដើម្បីស្វែងយល់បន្ថែមអំពីការអនុញ្ញាតជាមុន។ សូមមើលតារាងអត្ថប្រយោជន៍នៅក្នុងជំពូកទី 4 នៃ *សៀវភៅណែនាំសមាជិក* ដើម្បីស្វែងយល់ថាតើសេវាកម្មមួយណាដែលត្រូវការការអនុញ្ញាតជាមុន។ ប្រសិនបើអ្នកមានសំណួរថាតើការអនុញ្ញាតជាមុនត្រូវបានទាមទារសម្រាប់សេវាកម្ម នីតិវិធី បរិក្ខារ ឬឱសថជាក់លាក់ដែរឬទេ សូមទូរសព្ទទៅផ្នែកសេវាបម្រើអ្នកចុះឈ្មោះតាមរយៈលេខដែលបានរាយនៅផ្នែកខាងក្រោមនៃទំព័រនេះសម្រាប់ជំនួយ។
អ្វីទៅជាការបញ្ជូនបន្ត?	ការបញ្ជូនបន្តមានន័យថាអ្នកផ្តល់សេវាថែទាំបឋម (PCP) របស់អ្នកត្រូវតែផ្តល់ឱ្យអ្នកនូវការយល់ព្រមដើម្បីទៅជួបនរណាម្នាក់ដែលមិនមែនជា PCP របស់អ្នក។ ការបញ្ជូនបន្តគឺខុសពីការអនុញ្ញាតជាមុន។ ប្រសិនបើអ្នកមិនទទួលបានការបញ្ជូនបន្តពី PCP របស់អ្នកទេនោះ NaviCare ប្រហែលជាមិនគ្របដណ្តប់សេវានោះទេ។ NaviCare អាចផ្តល់ឱ្យអ្នកនូវបញ្ជីសេវាដែលតម្រូវឱ្យអ្នកទទួលបានការបញ្ជូនបន្តពី PCP របស់អ្នក មុនពេលសេវានោះត្រូវផ្តល់ជូន។ អ្នកមិនត្រូវការការបញ្ជូនបន្តដើម្បីជួបអ្នកឯកទេសជាក់លាក់ដូចជាអ្នកឯកទេសសុខភាពស្ត្រីនោះឡើយ។ សូមមើល *សៀវភៅណែនាំសមាជិក* ដើម្បីស្វែងយល់បន្ថែមអំពីពេលណាដែលអ្នកនឹងត្រូវការការបញ្ជូនបន្តពី PCP របស់អ្នក។

សំណួរដែលគេសួរញឹកញាប់ (FAQ) *បន្ត*

សំណួរដែលគេច្រើនសួរ	ចម្លើយ
តើខ្ញុំត្រូវទូទាត់ប្រាក់ប្រចាំខែ (ត្រូវបានហៅថាថ្លៃធានារ៉ាប់រងផងដែរ) ស្ថិតក្រោម NaviCare ដែរឬទេ?	សមាជិកភាគច្រើននឹងមិនចាំបាច់បង់ថ្លៃធានារ៉ាប់រងប្រចាំខែ រួមទាំងថ្លៃធានារ៉ាប់រង Medicare ផ្នែក B សម្រាប់ការធានារ៉ាប់រងសុខភាពរបស់ពួកគេឡើយ។ សមាជិក MassHealth (Medicaid) មួយចំនួនដែលមានប្រាក់ចំណូលខ្ពស់អាចនឹងត្រូវបង់ថ្លៃធានារ៉ាប់រងរបស់ Medicare ផ្នែក B។ លើសពីនេះទៀត ប្រសិនបើអ្នកបង់ថ្លៃធានារ៉ាប់រងដល់ MassHealth (Medicaid) អ្នកត្រូវតែបន្តបង់ថ្លៃធានារ៉ាប់រងដល់ MassHealth (Medicaid) ដើម្បីរក្សាការធានារ៉ាប់រងរបស់អ្នក។ សម្រាប់ព័ត៌មានបន្ថែម សូមទូរសព្ទទៅផ្នែកសេវាបម្រើអតិថិជនរបស់ MassHealth (Medicaid) តាមរយៈលេខ 1-800-841-2900 ឬ 711 សម្រាប់អ្នកដែលមានការលំបាកក្នុងការស្តាប់ ឬនិយាយ។ អ្នកត្រូវតែមានឧបករណ៍ទូរសព្ទពិសេសដើម្បីហៅវា។
តើខ្ញុំត្រូវបង់ប្រាក់មុនក្នុងនាមជាសមាជិករបស់ NaviCare ដែរឬទេ?	ទេ។ អ្នកមិនត្រូវបង់ប្រាក់មុននៅក្នុង NaviCare ទេ។
តើអ្វីជាចំនួនទឹកប្រាក់ចេញពីហោប៉ៅជាអតិបរមាដែលខ្ញុំនឹងត្រូវទូទាត់សម្រាប់សេវាវេជ្ជសាស្ត្រក្នុងនាមជាសមាជិករបស់ NaviCare?	មិនមានការចែករំលែកថ្លៃចំណាយសម្រាប់សេវាវេជ្ជសាស្ត្រនៅក្នុង NaviCare ទេ ដូច្នេះថ្លៃចំណាយចេញពីហោប៉ៅប្រចាំឆ្នាំរបស់អ្នកនឹងមានចំនួន $0។
តើអ្នកសម្របសម្រួលសេវាជំនួយមនុស្សចាស់ (GSSC) គឺជាអ្វី?	NaviCare GSSC គឺជាបុគ្គលម្នាក់នៅក្នុងក្រុមថែទាំរបស់អ្នកដែលជាអ្នកជំនាញខាងសេវាកម្ម និងការគាំទ្ររយៈពេលវែង និង/ឬសេវាកម្មសង្គ្រោះ។ បុគ្គលនេះជួយអ្នកឱ្យទទួលបានសេវាកម្មដែលជួយអ្នកឱ្យរស់នៅដោយមិនមានការកែប្រែនៅផ្ទះរបស់អ្នក។ សូមប្រាប់អ្នកស្វែងរកសេវារបស់អ្នក ប្រសិនបើអ្នកចាប់អារម្មណ៍លើការបញ្ជូនទៅ GSSC។
ចុះបើខ្ញុំរស់នៅក្នុងមណ្ឌលថែទាំរយៈពេលវែង?	ប្រសិនបើអ្នកជា—ឬក្លាយជា—អ្នករស់នៅក្នុងមណ្ឌលថែទាំរយៈពេលវែង អ្នកត្រូវតែបន្តបង់ចំនួនប្រាក់ដែលអ្នកជំងឺបានបង់ (PPA) របស់អ្នកទៅមណ្ឌលថែទាំមនុស្សចាស់។ PPA គឺជាចំណែកនៃប្រាក់ចំណូលប្រចាំខែដែលសមាជិកនៅក្នុងមណ្ឌលថែទាំត្រូវតែរួមចំណែកដល់ការចំណាយលើការថែទាំ។

C. បញ្ជីសេវាដែលមានការគ្របដណ្តប់

តារាងខាងក្រោមនេះគឺជាការសង្ខេបខ្លីនៃសេវាកម្មដែលអ្នកត្រូវការ ការចំណាយនិងច្បាប់អត្ថប្រយោជន៍របស់អ្នក។

តម្រូវការ ឬកង្វល់ផ្នែកសុខភាព	សេវាកម្មដែលអ្នកអាចនឹងត្រូវការ	ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ	ដែនកំណត់ ករណីលើកលែង និងព័ត៌មានអត្ថប្រយោជន៍ (ច្បាប់អំពីអត្ថប្រយោជន៍)
អ្នកត្រូវការថែទាំពីមន្ទីរពេទ្យ	ការស្នាក់នៅមន្ទីរពេទ្យរបស់អ្នកជំងឺស្នាក់ព្យាបាល	$0	តម្រូវឱ្យមានការអនុញ្ញាតជាមុន។ ការបញ្ជូនបន្តពី PCP។
	សេវាពិគ្រោះនៅមន្ទីរពេទ្យរួមទាំងការពិនិត្យមើល	$0	អាចតម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្តពី PCP។
	សេវាកម្មមជ្ឈមណ្ឌលវះកាត់ចល័ត (ASC)	$0	តម្រូវឱ្យមានការអនុញ្ញាតជាមុន។ ការបញ្ជូនបន្តពី PCP។
	ការថែទាំដោយវេជ្ជបណ្ឌិតឬការវះកាត់	$0	អាចត្រូវការការអនុញ្ញាតជាមុន។
អ្នកចង់បានវេជ្ជបណ្ឌិត	ការទៅជួបដើម្បីព្យាបាលរបួសឬជំងឺ	$0	
	ការថែទាំដើម្បីរក្សាសុខភាពអ្នកពីការឈឺដូចជាការចាក់ថ្នាំបង្ការនិងការឆ្លុះពិនិត្យរកមើលជំងឺមហារីក	$0	អាចត្រូវការការអនុញ្ញាតជាមុន។
	ជំនួបខាងសុខុុមាលភាពដូចជាផ្នែករាងកាយ	$0	
	“សូមស្វាគមន៍មកកាន់ Medicare” (ការជួបដើម្បីបង្ការជំងឺតែម្តងប៉ុណ្ណោះ)	$0	
	ការថែទាំឯកទេស	$0	អាចតម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្តពី PCP។
	ការដឹកជញ្ជូនទៅការិយាល័យវេជ្ជបណ្ឌិត	$0	អាចត្រូវការការអនុញ្ញាតជាមុន។

បញ្ជីសេវាដែលមានការធានារ៉ាប់រង *បន្ត*

តម្រូវការ ឬកង្វល់ផ្នែកសុខភាព	សេវាកម្មដែលអ្នកអាចនឹងត្រូវការ	ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ	ដែនកំណត់ ករណីលើកលែង និងព័ត៌មានអត្ថប្រយោជន៍ (ច្បាប់អំពីអត្ថប្រយោជន៍)
អ្នកត្រូវការការថែទាំសង្គ្រោះបន្ទាន់	សេវាបន្ទប់សង្គ្រោះបន្ទាន់	$0	សេវាបន្ទប់សង្គ្រោះបន្ទាន់ត្រូវបានធានារ៉ាប់រងនៅទូទាំងពិភពលោក ទាំងនៅក្នុង និងក្រៅបណ្តាញ ហើយមិនត្រូវការការអនុញ្ញាតជាមុនទេ។
	ការថែទាំបន្ទាន់	$0	សេវាថែទាំបន្ទាន់ត្រូវបានធានារ៉ាប់រងនៅទូទាំងពិភពលោក ទាំងនៅក្នុង និងក្រៅបណ្តាញ ហើយមិនត្រូវការការអនុញ្ញាតជាមុនទេ។
អ្នកត្រូវការការធ្វើតេស្តវេជ្ជសាស្ត្រ	សេវាពិនិត្យរោគវិនិច្ឆ័យដោយវិទ្យសកម្ម (ឧទាហរណ៍ ការថតកាំរស្មីអ៊ិច ឬសេវាថតរូបភាពផ្សេងទៀត ដូចជាការស្កែន CAT ឬ MRI)	$0	អាចតម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្តពី PCP។
	ធ្វើតេស្តនៅក្នុងមន្ទីរពិសោធន៍និងនីតិវិធីធ្វើរោគវិនិច្ឆ័យដូចជាការពិនិត្យឈាម	$0	អាចតម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្តពី PCP។
	ការធ្វើតេស្តពិនិត្យដូចជាការធ្វើតេស្តដើម្បីរកមើលជំងឺមហារីក	$0	អាចតម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្តពី PCP។
អ្នកត្រូវការសេវាកម្មសុខភាពត្រចៀក	ការពិនិត្យសុខភាពត្រចៀករួមមាន៖	$0	អាចត្រូវការការអនុញ្ញាតជាមុន។
	ឧបករណ៍ជំនួយការស្តាប់	$0	ឧបករណ៍ជំនួយការស្តាប់មួយ (1) ក្នុងមួយត្រចៀករៀងរាល់ 60 ខែម្តង។

បញ្ជីសេវាដែលមានការធានារ៉ាប់រង *បន្ត*

តម្រូវការ ឬកង្វល់ផ្នែកសុខភាព	សេវាកម្មដែលអ្នកអាចនឹងត្រូវការ	ការចំណាយរបស់អ្នកសម្រាប់ អ្នកផ្តល់សេវានៅក្នុងបណ្តាញ	ដែនកំណត់ ករណីលើកលែង និងព័ត៌មានអត្ថប្រយោជន៍ (ច្បាប់អំពីអត្ថប្រយោជន៍)
អ្នកត្រូវការការថែទាំធ្មេញ	ការពិនិត្យធ្មេញនិងការថែទាំបង្ការសុខភាពធ្មេញ	$0	
	ការថែទាំនិងការជួសជុលធ្មេញជាបន្ទាន់ (សម្រាប់ព័ត៌មានបន្ថែម សូមមើល *សៀវភៅណែនាំសមាជិក* NaviCare HMO SNP និង NaviCare NHC HMO SNP) បញ្ជីអ្នកផ្តល់សេវាសុខភាពធ្មេញមាននៅលើអនឡាញនៅ fallonhealth.org/navicare	$0	អាចត្រូវការការអនុញ្ញាតជាមុន។ ត្រូវអនុវត្តដែនកំណត់ភាពញឹកញាប់នៃអត្ថប្រយោជន៍។ រួមបញ្ចូល៖ • ការថតកាំរស្មីអ៊ិចធ្មេញ • ការប៉ះធ្មេញ ការស្រោបធ្មេញ ការដកធ្មេញ ការវះកាត់ដាក់ធ្មេញ ការវះកាត់ក្នុងមាត់ និងប្រហោងឫសធ្មេញ
អ្នកត្រូវការការថែសុខភាពភ្នែក	ការពិនិត្យភ្នែក	$0	ការពិនិត្យជាប្រចាំ (1 ដងក្នុងមួយឆ្នាំ)
	វ៉ែនតាឬកែវដាក់ក្នុងភ្នែក	$0	រួមបញ្ចូល៖ • វ៉ែនតា ឬកែវដាក់ក្នុងភ្នែកដែលរ៉ាប់រងដោយ Medicare មួយ (1) គូបន្ទាប់ពីការវះកាត់ជំងឺភ្នែកឡើងបាយ • វ៉ែនតាដល់ទៅ 2 គូ កញ្ចក់វ៉ែនតា កែវពាក់លើគ្រាប់ភ្នែក ស៊ីម ឬការដំឡើងកម្រិតរហូតដល់ចំនួនកំណត់នៃការធានារ៉ាប់រងប្រចាំឆ្នាំរបស់គម្រោង $403
	ការពិនិត្យសុខភាពភ្នែកផ្សេងទៀត	$0	រួមបញ្ចូល៖ • ការធ្វើតេស្តជំងឺទឹកដក់ក្នុងភ្នែកដែលធានារ៉ាប់រងដោយ Medicare • ការពិនិត្យដែលរ៉ាប់រងដោយ Medicare ដើម្បីព្យាបាលជំងឺភ្នែក

បញ្ជីសេវាដែលមានការធានារ៉ាប់រង *បន្ត*

តម្រូវការ ឬកង្វល់ផ្នែកសុខភាព	សេវាកម្មដែលអ្នកអាចនឹងត្រូវការ	ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ	ដែនកំណត់ ករណីលើកលែង និងព័ត៌មានអត្ថប្រយោជន៍ (ច្បាប់អំពីអត្ថប្រយោជន៍)
អ្នកត្រូវការសេវាសុខភាពអាកប្បកិរិយា	សេវាសុខភាពឥរិយាបថ	$0	អ្នកជំងឺស្នាក់ព្យាបាល៖ តម្រូវឱ្យមានការអនុញ្ញាតជាមុន។ ការព្យាបាលដោយរំញោចម៉ាញេទិច (TMS) ការព្យាបាលដោយរំញោចអគ្គិសនី (ECT) និងការព្យាបាលអ្នកជំងឺមិនស្នាក់ព្យាបាលកម្រិតធ្ងន់ (IOP) តម្រូវឱ្យមានការអនុញ្ញាតជាមុន។ អាចទាមទារការបញ្ជូនបន្តពី PCP ។
	ការថែទាំអ្នកជំងឺសម្រាកមន្ទីរពេទ្យ និងការពិគ្រោះអ្នកជំងឺនិងសេវាតាមសហគមន៍សម្រាប់អ្នកដែលត្រូវការតំហែទាំសុខភាពផ្លូវចិត្ត	$0	អ្នកជំងឺក្នុងមន្ទីរពេទ្យ៖: ត្រូវការការអនុញ្ញាតជាមុន។ រួមបញ្ចូល៖ • ការជួបពិគ្រោះព្យាបាលអ្នកជំងឺមិនស្នាក់ព្យាបាលជាបុគ្គល ឬជាក្រុមដោយមាន ឬគ្មានគ្រូពេទ្យវិកលចរិក • សេវាបង្វែរ ដូចជា៖ ○ ការអង្កេត ○ សេវាកម្មជំនួយសហគមន៍ ○ ការវាយតម្លៃវិបត្តិ អន្តរាគមន៍ និងស្ថិរភាព ○ ការព្យាបាលផ្នែកចិត្តសាស្ត្រប្រចាំថ្ងៃ • សេវាសង្គ្រោះបន្ទាន់ផ្នែកសុខភាពអាកប្បកិរិយា • សេវាកម្មគ្រប់គ្រងឱសថ • កម្មវិធីព្យាបាលនៅតាមផ្ទះនៅពេលថ្ងៃ

បញ្ជីសេវាដែលមានការធានារ៉ាប់រង *បន្ត*

តម្រូវការ ឬកង្វល់ផ្នែកសុខភាព	សេវាកម្មដែលអ្នកអាចនឹងត្រូវការ	ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ	ដែនកំណត់ ករណីលើកលែង និងព័ត៌មានអត្ថប្រយោជន៍ (ច្បាប់អំពីអត្ថប្រយោជន៍)
អ្នកត្រូវការសេវាព្យាបាលវិបត្តិផ្លូវចិត្តដោយការប្រើប្រាស់សារធាតុញៀន	សេវាកម្មលើវិបត្តិដែលបណ្តាលមកពីការប្រើប្រាស់សារធាតុញៀន	$0	អ្នកជំងឺស្នាក់ព្យាបាល៖ MassHealth (Medicaid) រ៉ាប់រងលើការស្នាក់នៅមន្ទីរពេទ្យរបស់អ្នកលើសពីដែនកំណត់ 90 ថ្ងៃដែលចាំបាច់ខាងវេជ្ជសាស្ត្រ។ តម្រូវឱ្យមានការអនុញ្ញាតជាមុន។ ការព្យាបាលអ្នកជំងឺមិនស្នាក់ព្យាបាលកម្រិតធ្ងន់ (IOP) តម្រូវឱ្យមានការអនុញ្ញាតជាមុន។ សេវាកម្មដែលរ៉ាប់រងសម្រាប់អ្នកជំងឺមិនស្នាក់ព្យាបាល រួមមានជាអាទិ៍៖ • ការព្យាបាលផ្លូវចិត្ត (ការជួបពិគ្រោះព្យាបាលជាបុគ្គល ឬជាក្រុម) • ការអប់រំសមាជិកទាក់ទងនឹងការធ្វើរោគវិនិច្ឆយ និងការព្យាបាល MassHealth (Medicaid) រ៉ាប់រងលើសេវាកម្មបន្ថែម រួមមាន៖ • ការចាក់ម្ជុលវិទ្យាសាស្ត្រ ○ ការធានារ៉ាប់រងរួមបញ្ចូលទាំងការព្យាបាលគ្មានដែនកំណត់ជាមួយគ្រូពេទ្យចាក់ម្ជុលវិទ្យាសាស្ត្រក្នុងបណ្តាញ • ការថែទាំដោយថ្នាំ Methadone • កម្មវិធីញៀនអ្នកជំងឺក្រៅរចនាសម្ព័ន្ធ • សេវាគាំទ្រគ្លីនិក • សេវាស្តារនីតិសម្បទាសម្រាប់មនុស្សពេញវ័យ • កម្មវិធីនៃការព្យាបាលដោយសហគមន៍អះអាង (PACT) • សេវាកម្មជំនួយសហគមន៍ • ការវាយតម្លៃវិបត្តិ អន្តរាគមន៍ និងស្ថិរភាព សូមទាក់ទងមជ្ឈមណ្ឌលសុខភាពអាកប្បកិរិយាសហគមន៍ (CBHC) តាមលេខ 1-877-382-1609 ដើម្បីស្វែងរកសេវាវិបត្តិការប្រើប្រាស់សារធាតុញៀនដែលនៅជិតអ្នក។

បញ្ជីសេវាដែលមានការធានារ៉ាប់រង *បន្ត*

សេចក្តីសង្ខេបនៃអត្ថប្រយោជន៍របស់ NaviCare HMO SNP និង NaviCare NHC HMO SNP

តម្រូវការ ឬកង្វល់ផ្នែកសុខភាព	សេវាកម្មដែលអ្នកអាចនឹងត្រូវការ	ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ	ដែនកំណត់ ករណីលើកលែង និងព័ត៌មានអត្ថប្រយោជន៍ (ច្បាប់អំពីអត្ថប្រយោជន៍)
អ្នកត្រូវការកន្លែងដើម្បីរស់នៅជាមួយមនុស្សដែលអាចជួយអ្នក	ការថែទាំពីគិលានុប្បដ្ឋាកាជំនាញ	$0	តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្តពី PCP។
	ការថែទាំនៅតាមគេហដ្ឋាន	$0	តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្តពី PCP។ ប្រសិនបើ MassHealth (Medicaid) កំណត់ថាអ្នកមានចំនួនទឹកប្រាក់បង់ថ្លៃអ្នកជំងឺ (PPA) ប្រចាំខែ អ្នកទទួលខុសត្រូវចំពោះការបង់ប្រាក់ PPA។
	ការថែទាំមនុស្សពេញវ័យដោយគ្រួសារធម៌ និងការថែទាំមនុស្សពេញវ័យជាក្រុមដោយគ្រួសារធម៌	$0	តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្តពី PCP។ នេះអាចរួមមានការថែទាំប្រចាំថ្ងៃដូចជាការគ្រប់គ្រងអនាម័យខ្លួនប្រាណ ការមើលការខុសត្រូវចំពោះការប្រើឱសថ អាហារ អាហារសម្រន់ ការរៀបចំផ្ទះ ការបោកខោអាវនិងការដឹកជញ្ជូនផ្នែកវេជ្ជសាស្ត្រ ពីអ្នកផ្តល់សេវាមើលថែមនុស្សពេញវ័យឬសេវាមើលថែក្រុមមនុស្សពេញវ័យដែលមានលក្ខណៈគ្រប់គ្រាន់ដែលមានការយល់ព្រមពីរដ្ឋនិងដែលមានលក្ខណៈគ្រប់គ្រាន់។
អ្នកត្រូវការការព្យាបាល បន្ទាប់ពីមានជំងឺដាច់សរសៃឈាមខួរក្បាលឬគ្រោះថ្នាក់	ការព្យាបាលចលនា រាងកាយ ឬការព្យាបាលឱ្យចេះនិយាយឡើងវិញ	$0	ការទៅជួបព្យាបាលដោយចលនា និងការងារលើសពីការទៅជួបលើកទី 60 ម្តងៗត្រូវការការអនុញ្ញាតជាមុន។ ការទៅជួបព្យាបាលភាសានិយាយលើសពីការទៅជួបលើកទី 35 ត្រូវការការអនុញ្ញាតជាមុន ។

បញ្ជីសេវាដែលមានការធានារ៉ាប់រង *បន្ត*

តម្រូវការ ឬកង្វល់ផ្នែកសុខភាព	សេវាកម្មដែលអ្នកអាចនឹងត្រូវការ	ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ	ដែនកំណត់ ករណីលើកលែង និងព័ត៌មានអត្ថប្រយោជន៍ (ច្បាប់អំពីអត្ថប្រយោជន៍)
អ្នកត្រូវការជំនួយក្នុងការទទួលបានសេវាសុខភាព	សេវាកម្មរថយន្តសង្គ្រោះ	$0	សេវារថយន្តពេទ្យដែលមិនមែនសង្គ្រោះបន្ទាន់តម្រូវឱ្យមានការអនុញ្ញាតជាមុន។
	ការដឹកជញ្ជូនពេលមានអាសន្ន	$0	ការធានារ៉ាប់រងទូទាំងពិភពលោក។
	មធ្យោបាយធ្វើដំណើរទៅការណាត់ជួបវេជ្ជសាស្ត្រនិងសេវាកម្មនានា	$0	ការជិះគ្មានដែនកំណត់ទៅ និងមកពីការណាត់ជួបផ្នែកវេជ្ជសាស្ត្រ និងកន្លែងដែលអ្នកទទួលបានការថែទាំសុខភាព ដូចជាការទៅជួបនៅការិយាល័យវេជ្ជបណ្ឌិត ការព្យាបាលដោយចលនា ការប្រឹក្សាយោបល់ និងការទៅមន្ទីរពេទ្យ។ ទទួលបានការជិះពីសេវាកម្មជាដៃគូរបស់ Fallon Health ឬពីមិត្តភក្តិ និងក្រុមគ្រួសាររបស់អ្នកផ្ទាល់ ដែលអាចទទួលបានសំណងសម្រាប់ចម្ងាយនៃការជិះដែលត្រូវបានអនុម័តជាមុន។
អ្នកត្រូវការឱសថដើម្បីព្យាបាលជំងឺឬស្ថានភាពរបស់អ្នក *(តទៅទំព័របន្ទាប់)*	ឱសថ Medicare ផ្នែក B	$0	អាចត្រូវការការអនុញ្ញាតជាមុន។ ឱសថផ្នែក B រួមបញ្ចូលទាំងឱសថ ដែលផ្តល់ដោយវេជ្ជបណ្ឌិតរបស់អ្នកនៅការិយាល័យរបស់ពួកគេ ឱសថជំងឺមហារីកលេបតាមមាត់មួយចំនួន និងឱសថមួយចំនួនដែលប្រើជាមួយឧបករណ៍វេជ្ជសាស្ត្រជាក់លាក់មួយចំនួន។ សូមអាន *សៀវភៅណែនាំសមាជិក* សម្រាប់ព័ត៌មានបន្ថែមអំពីឱសថទាំងនេះ។

បញ្ជីសេវាដែលមានការធានារ៉ាប់រង *បន្ត*

តម្រូវការ ឬកង្វល់ផ្នែកសុខភាព	សេវាកម្មដែលអ្នកអាចនឹងត្រូវការ	ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ	ដែនកំណត់ ករណីលើកលែង និងព័ត៌មានអត្ថប្រយោជន៍ (ច្បាប់អំពីអត្ថប្រយោជន៍)
អ្នកត្រូវការឱសថដើម្បីព្យាបាលជំងឺឬស្ថានភាពរបស់អ្នក *(បន្តពីទំព័រមុន)*	ឱសថ Medicare ផ្នែក D ឱសថទូទៅ (គ្មានម៉ាកយីហោ) កម្រិត 1៖ ឱសថម៉ាកយីហោ និងទូទៅ	$0 សម្រាប់ការផ្គត់ផ្គង់រយៈពេល 30 ថ្ងៃ	អាចនឹងមានកំណត់ចំពោះប្រភេទឱសថដែលស្ថិតក្នុងការធានារ៉ាប់រង។ សូមមើល បញ្ជីឱសថដែលមានការធានារ៉ាប់រងរបស់ NaviCare *(បញ្ជីឱសថ)* សម្រាប់ព័ត៌មានបន្ថែម។ ការផ្គត់ផ្គង់បន្ថែមថ្ងៃអាចរកបានសម្រាប់ឱសថភាគច្រើនតាមរយៈការបញ្ជាទិញតាមប្រៃសណីយ៍ និងឱសថស្ថានលក់រាយមួយចំនួន ដោយគ្មានការចែករំលែកថ្លៃចំណាយ។
	ឱសថដែលអ្នកអាចទទួលបានដោយគ្មានវេជ្ជបញ្ជា (OTC)	$0	អាចនឹងមានកំណត់ចំពោះប្រភេទឱសថដែលស្ថិតក្នុងការធានារ៉ាប់រង។ សូមមើល បញ្ជីឱសថដែលមានការធានារ៉ាប់រងរបស់ NaviCare HMO SNP និង NaviCare NHC HMO SNP *(បញ្ជីឱសថ)* សម្រាប់ព័ត៌មានបន្ថែម។
អ្នកត្រូវការជំនួយឱ្យសុខភាពប្រសើរឡើង ឬមានតម្រូវការសុខភាពពិសេស	សេវាស្តារនីតិសម្បទា	$0	អាចត្រូវការការអនុញ្ញាតជាមុន។ ការស្តារនីតិសម្បទាបេះដូង (បេះដូង) តម្រូវឱ្យមានការបញ្ជូនពី PCP សម្រាប់វគ្គមួយម៉ោងចំនួន 2 លើកជាអតិបរមា ក្នុងមួយថ្ងៃរហូតដល់ចំនួន 36 វគ្គសម្រាប់រយៈពេលរហូតដល់ 36 សប្តាហ៍។
	ឧបករណ៍វេជ្ជសាស្ត្រសម្រាប់ការថែទាំតាមផ្ទះ	$0	តម្រូវឱ្យមានការអនុញ្ញាតជាមុន។
	សេវាវះកាត់លាងតំរងនោម	$0	
អ្នកត្រូវការការថែទាំជើង	សេវាកម្មព្យាបាលបាតជើង	$0	រួមបញ្ចូលទាំងការជួបដែលរ៉ាប់រងដោយ Medicare និង MassHealth (Medicaid) ដូចជាការជួបសម្រាប់ការកាត់ក្រចក។ តម្រូវឱ្យមានការអនុញ្ញាតជាមុនសម្រាប់សេវាកម្មនៅក្នុងមណ្ឌលថែទាំមនុស្សចាស់ និងការវះកាត់ជើង។
	សេវាកម្មអូតូស	$0	តម្រូវឱ្យមានការអនុញ្ញាតជាមុន។

បញ្ជីសេវាដែលមានការធានារ៉ាប់រង *បន្ត*

តម្រូវការ ឬកង្វល់ផ្នែកសុខភាព	សេវាកម្មដែលអ្នកអាចនឹងត្រូវការ	ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ	ដែនកំណត់ ករណីលើកលែង និងព័ត៌មានអត្ថប្រយោជន៍ (ច្បាប់អំពីអត្ថប្រយោជន៍)
អ្នកត្រូវការឧបករណ៍វេជ្ជសាស្ត្រសម្រាប់ប្រើរយៈពេលយូរ (DME) ចំណាំ៖ នេះមិនមែនជាបញ្ជីពេញលេញនៃ DME ដែលបានធានារ៉ាប់រងទេ។ សម្រាប់បញ្ជីពេញលេញ សូមទាក់ទងសេវាអ្នកចុះឈ្មោះ ឬមើលជំពូកទី 4 នៃ *សៀវភៅណែនាំសមាជិក*។	រទេះរុញ ឈើច្រត់និងឧបករណ៍ជំនួយការដើរ	$0	តម្រូវឱ្យមានការអនុញ្ញាតជាមុន។
	ម៉ាស៊ីនឆ្នុង	$0	តម្រូវឱ្យមានការអនុញ្ញាតជាមុន។
	ឧបករណ៍ អុកស៊ីសែន និងការផ្គត់ផ្គង់	$0	តម្រូវឱ្យមានការអនុញ្ញាតជាមុន។
អ្នកត្រូវការជំនួយក្នុងការរស់នៅផ្ទះ *(តទៅទំព័របន្ទាប់)*	សេវាសុខភាពតាមផ្ទះ	$0	តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្តពី PCP។
	សេវាតាមផ្ទះ ដូចជាការសម្អាត ឬការថែទាំផ្ទះ ឬការកែប្រែផ្ទះដូចជារបារចាប់កាន់តោង	$0	តម្រូវឱ្យមានការអនុញ្ញាតជាមុន។ ការបញ្ជូនបន្តពី PCP។ ទាក់ទងអ្នកស្វែងរកសេវារបស់អ្នកសម្រាប់ព័ត៌មានអំពីរបៀបទទួលបានសេវាកម្មទាំងនេះ។
	សេវាសុខភាពមនុស្សពេញវ័យពេលថ្ងៃឬសេវាកម្មគាំទ្រផ្សេងៗទៀត	$0	តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្តពី PCP។ នេះអាចរួមបញ្ចូលសេវាកម្មតាមសហគមន៍ ដូចជាការថែទាំសុខភាព ជំនួយជាមួយសកម្មភាពនៃការរស់នៅប្រចាំថ្ងៃ សង្គម ការព្យាបាល ការកម្សាន្ត អាហារូបត្ថម្ភនៅកន្លែងក្រៅផ្ទះ អន្តរកម្មជាក់លាក់សម្រាប់ជំងឺវង្វេង និងការដឹកជញ្ជូនទៅកន្លែងសុខភាពមនុស្សពេញវ័យដែលចុះកិច្ចសន្យាជាមួយ NaviCare នៅខាងក្រៅផ្ទះ។ ទាក់ទងអ្នកស្វែងរកសេវារបស់អ្នកសម្រាប់ព័ត៌មានអំពីរបៀបទទួលបានសេវាកម្មទាំងនេះ។

បញ្ជីសេវាដែលមានការធានារ៉ាប់រង *បន្ត*

តម្រូវការ ឬកង្វល់ផ្នែកសុខភាព	សេវាកម្មដែលអ្នកអាចនឹងត្រូវការ	ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ	ដែនកំណត់ ករណីលើកលែង និងព័ត៌មានអត្ថប្រយោជន៍ (ច្បាប់អំពីអត្ថប្រយោជន៍)
អ្នកត្រូវការជំនួយក្នុងការរស់នៅផ្ទះ *(តពីទំព័រមុន)*	សេវាស្តារសមត្ថភាពនាពេលថ្ងៃ	$0	តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្តពី PCP។ នេះរួមបញ្ចូលទាំងកម្មវិធីព្យាបាលដែលមានលក្ខណៈសកម្មជាប្រព័ន្ធ ដែលមានគោលដៅជាក់លាក់នៃសេវាស្តារសមត្ថភាពនិងការព្យាបាលដែលមានគោលដៅខាងផ្នែកវេជ្ជសាស្ត្រសម្រាប់បុគ្គលដែលកំពុងរកទទួលពិការភាពនិងដែលត្រូវការការព្យាបាលយ៉ាងសកម្ម។
	សេវាកម្មដើម្បីជួយអ្នករស់នៅដោយខ្លួនឯង (សេវាថែទាំសុខភាពតាមផ្ទះឬសេវាអ្នកថែទាំផ្ទាល់ខ្លួន)	$0	តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្តពី PCP។ នេះរួមបញ្ចូលទាំងជំនួយរាងកាយជាមួយសកម្មភាពនៃការរស់នៅប្រចាំថ្ងៃ (ADL) មិនកំណត់ចំពោះការងូតទឹក ការស្លៀកពាក់ ការតុបតែងខ្លួន ការញ៉ាំ ការចល័ត/ផ្លាស់ទី ការប្រើបង្គន់ ការចេញការប្រើថ្នាំ និងការធ្វើលំហាត់ប្រាណដោយចលនាអកម្ម និងសកម្មភាពរស់នៅប្រចាំថ្ងៃសំខាន់ៗ (IADL) រួមមានជាអាទិ៍ កិច្ចការគ្រប់គ្រងផ្ទះសម្បែង ការរៀបចំអាហារ និងការដឹកជញ្ជូនទៅកាន់អ្នកផ្តល់សេវាវេជ្ជសាស្ត្រ។ ទាក់ទងអ្នកស្វែងរកសេវារបស់អ្នកសម្រាប់ព័ត៌មានអំពីរបៀបទទួលបានសេវាកម្មទាំងនេះ។

បញ្ជីសេវាដែលមានការធានារ៉ាប់រង *បន្ត*

តម្រូវការ ឬកង្វល់ផ្នែកសុខភាព	សេវាកម្មដែលអ្នកអាចនឹងត្រូវការ	ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ	ដែនកំណត់ ករណីលើកលែង និងព័ត៌មានអត្ថប្រយោជន៍ (ច្បាប់អំពីអត្ថប្រយោជន៍)
សេវាកម្មបន្ថែម *(តទៅទំព័របន្ទាប់)*	សេវាកម្មចាប់សរសៃ	$0	
	សម្ភារៈផ្គត់ផ្គង់និងសេវាកម្មជំងឺទឹកនោមផ្អែម	$0	អាចត្រូវការការអនុញ្ញាតជាមុន។ រួមបញ្ចូលទាំងការពិនិត្យតាមដានជាតិស្ករក្នុងឈាមនិងការធ្វើតេស្តឈាមការហ្វឹកហាត់និងស្បែកជើងគ្រប់គ្រងទឹកនោមផ្អែមដោយខ្លួនឯង.
	សេវាកម្មជំនួសសរីរាង្គដែលកាត់ចោល	$0	តម្រូវឱ្យមានការអនុញ្ញាតជាមុន។
	ការព្យាបាលដោយកាំរស្មី	$0	តម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្តពី PCP។
	សេវាកម្មដើម្បីជួយគ្រប់គ្រងជំងឺរបស់អ្នក	$0	អាចតម្រូវឱ្យមានការអនុញ្ញាតជាមុន និងការបញ្ជូនបន្តពី PCP។
	ការព្យាបាលពីចម្ងាយ	$0	រួមបញ្ចូលទាំងការថែទាំបឋម ការថែទាំឯកទេស សេវាសុខភាពអាកប្បកិរិយាសម្រាប់អ្នកជំងឺមិនស្ទាក់ព្យាបាល ការព្យាបាលសារធាតុអូផ្សអ៊ីតសម្រាប់អ្នកជំងឺមិនស្ទាក់ព្យាបាល និងសេវាព្យាបាលវិបត្តិនៃការប្រើប្រាស់សារធាតុញៀនសម្រាប់អ្នកជំងឺមិនស្ទាក់ព្យាបាល។ អាចរកគ្រូពេទ្យ 24/7 សម្រាប់ស្ថានភាពមិនបន្ទាន់តាមរយៈទូរសព្ទ ឬកម្មវិធីឧបករណ៍ចល័ត ឬ អនឡាញ។

បញ្ជីសេវាដែលមានការធានារ៉ាប់រង *បន្ត*

តម្រូវការ ឬកង្វល់ផ្នែកសុខភាព	សេវាកម្មដែលអ្នកអាចនឹងត្រូវការ	ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ	ដែនកំណត់ ករណីលើកលែង និងព័ត៌មានអត្ថប្រយោជន៍ (ច្បាប់អំពីអត្ថប្រយោជន៍)
សេវាកម្មបន្ថែម *(តពីទំព័រមុន)*	Care Connect	$0	អាចទទួលបានសេវាពីគិលានុបដ្ឋាយិកាដែលបានចុះបញ្ជី តាមទូរសព្ទ 24/7 ហើយគិលានុបដ្ឋាយិកានឹងធ្វើការណែនាំអំពីកន្លែងដែលអ្នកគួរទទួលយកការថែទាំ ឬនឹងភ្ជាប់ទំនាក់ទំនងអ្នកទៅកាន់គ្រូពេទ្យរបស់អ្នក។
	ការដឹកជញ្ជូនពេលដែលមិនបន្ទាន់	$0	អាចត្រូវការការអនុញ្ញាតជាមុន។ ការជិះមួយផ្លូវ 48 ដង (ក្នុងរង្វង់ចម្ងាយ 30 ម៉ាយល៍) ទៅកាន់ឱសថស្ថានក្នុងមួយឆ្នាំ។ ទទួលបានការជិះពីសេវាកម្មជាដៃគូរបស់ Fallon Health ឬមិត្តភក្តិ និងក្រុមគ្រួសាររបស់អ្នកផ្ទាល់ ដែលអាចទទួលបានសំណងសម្រាប់ចម្ងាយនៃការជិះដែលត្រូវបានអនុម័តជាមុន។ សមាជិកដែលមានបញ្ហាជំងឺរ៉ាំរ៉ៃដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ក៏មានសិទ្ធិប្រើការធ្វើដំណើរមួយជើងចំនួន 100 ដង* ក្នុងមួយឆ្នាំដើម្បីចេញទៅធ្វើកិច្ចការ ទៅជួបមិត្តភ័ក្តិ ចូលរួមក្នុងសេវាកម្មសាសនា និងច្រើនទៀត។ មិនមែនសមាជិកទាំងអស់សុទ្ធតែមានលក្ខណសម្បត្តិគ្រប់គ្រាន់នោះទេ។ ដើម្បីស្វែងយល់បន្ថែម សូមទាក់ទងមកយើងខ្ញុំតាមរយៈលេខដែលបានរាយនៅផ្នែកខាងក្រោមនៃទំព័រនេះ។
	សំណងផ្នែកសុខភាព	ការចំណាយលើស $400	$400 ក្នុងមួយឆ្នាំដើម្បីបង់ថ្លៃសម្រាប់ថ្នាក់ហាត់ប្រាណ ឧបករណ៍តាមដានកាយសម្បទាថ្មី ឧបករណ៍ហាត់ប្រាណសម្រាប់សរសៃឈាមបេះដូងថ្មី ឬសមាជិកភាពហាត់ប្រាណ/កន្លែងហាត់ប្រាណ

បញ្ជីសេវាដែលមានការធានារ៉ាប់រង *បន្ត*

តម្រូវការ ឬកង្វល់ផ្នែកសុខភាព	សេវាកម្មដែលអ្នកអាចនឹងត្រូវការ	ការចំណាយរបស់អ្នកសម្រាប់អ្នកផ្តល់សេវានៅក្នុងបណ្តាញ	ដែនកំណត់ ករណីលើកលែង និងព័ត៌មានអត្ថប្រយោជន៍ (ច្បាប់អំពីអត្ថប្រយោជន៍)
សេវាកម្មបន្ថែម *(តពីទំព័រមុន)*	បណ្ណ Save Now	ថ្លៃចំណាយខាងលើ $375 ក្នុងមួយត្រីមាស	ទទួលបាន $375 ក្នុងមួយត្រីមាសតាមប្រតិទិន នៅលើកាត Save Now។ ប្រើកាតដើម្បីទិញសម្ភារៈថែទាំសុខភាពនិងផ្នាល់ខ្លួនដូចជាថ្នាំផ្តាសាយ ថ្នាំដុសធ្មេញ និងសាប៊ូ។ អ្នកនឹងទទួលបានប្រាក់សរុបចំនួន $1,500 ក្នុងមួយឆ្នាំដែលអាចប្រើបាននៅក្នុងហាងឬសម្រាប់ការបញ្ជាទិញតាមអ៊ីនធឺណិតនិងទូរសព្ទ។ សមាជិកដែលមានបញ្ហាជំងឺរ៉ាំរ៉ៃដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ក៏អាចប្រើកាត Save Now ដើម្បីទិញអាហារសុខភាពផងដែរ។* មិនមែនសមាជិកទាំងអស់មានលក្ខណសម្បត្តិគ្រប់គ្រាន់នោះទេ។ ដើម្បីស្វែងយល់បន្ថែម សូមទាក់ទងមកយើងខ្ញុំតាមរយៈលេខដែលបានរាយនៅផ្នែកខាងក្រោមនៃទំព័រនេះ។

សេចក្តីសង្ខេបអំពីអត្ថប្រយោជន៍ខាងលើត្រូវបានផ្តល់ជូនសម្រាប់គោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ ហើយមិនមែនជាបញ្ជីពេញលេញនៃអត្ថប្រយោជន៍ទេ។ សម្រាប់បញ្ជីពេញលេញ និងព័ត៌មានបន្ថែមអំពីអត្ថប្រយោជន៍របស់អ្នក អ្នកអាចអាន *សៀវភៅណែនាំសមាជិក* NaviCare HMO SNP និង NaviCare NHC HMO SNP។ ប្រសិនបើអ្នកមិនមាន*សៀវភៅណែនាំសមាជិក*ទេសូមទូរសព្ទទៅផ្នែកប្រើសេវាអ្នកចុះឈ្មោះ NaviCare តាមរយៈលេខដែលបានរាយនៅខាងក្រោមទំព័រនេះ ដើម្បីទទួលបានមួយ។ ប្រសិនបើអ្នកមានសំណួរ អ្នកក៏អាចទូរសព្ទទៅផ្នែកបម្រើសេវាអ្នកចុះឈ្មោះ NaviCare ឬចូលមើលគេហទំព័រ fallonhealth.org/navicare។

**ការធ្វើដំណើរមួយជើងចំនួន 100 ដងក្នុងមួយឆ្នាំដើម្បីចេញទៅធ្វើកិច្ចការ ទៅជួបមិត្តភ័ក្តិ ចូលរួមក្នុងសេវាកម្មសាសនា និងច្រើនទៀត ហើយអត្ថប្រយោជន៍អាហារសុខភាពនៃកាត Save Now គឺជាផ្នែកមួយនៃកម្មវិធីបន្ថែមពិសេសសម្រាប់អ្នកជំងឺរ៉ាំរ៉ៃ។ ដើម្បីមានលក្ខណសម្បត្តិគ្រប់គ្រាន់ អ្នកចុះឈ្មោះត្រូវតែមានរោគវិនិច្ឆ័យស្ថានភាពរ៉ាំរ៉ៃដែលមានជាឯកសារជាមួយ Fallon Health ដូចជាជំងឺសរសៃឈាមបេះដូង ស្ថានភាពសុខភាពអាកប្បកិរិយារ៉ាំរ៉ៃនិងពិការភាព ជំងឺសួតរ៉ាំរ៉ៃ ជំងឺទឹកនោមផ្អែម និងជំងឺសរសៃប្រសាទ។ នេះមិនមែនជាបញ្ជីពេញលេញនៃលក្ខណៈរ៉ាំរ៉ៃដែលមានសិទ្ធិទទួលបាននោះទេ។ មិនមែនសមាជិកទាំងអស់ដែលមានលក្ខខណ្ឌគ្រប់សិទ្ធិទទួលបាន នឹងមានលក្ខណសម្បត្តិគ្រប់គ្រាន់នោះទេ។ លក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបាន និងការធានារ៉ាប់រងផ្សេងទៀតក៏ត្រូវប្រើផងដែរ។*

D. អត្ថប្រយោជន៍ដែលត្រូវបានគ្របដណ្តប់នៅក្រៅ NaviCare

មានសេវាកម្មមួយចំនួនដែលអ្នកអាចទទួលបាន ដែលមិនត្រូវបានធានារ៉ាប់រងដោយ NaviCare ប៉ុន្តែត្រូវបានធានារ៉ាប់រងដោយ Medicare, MassHealth (Medicaid) ឬទីភ្នាក់ងាររដ្ឋ ឬខោនធី។ នេះមិនមែនជាបញ្ជីពេញលេញទេ។ សូមទូរសព្ទទៅផ្នែកបម្រើសេវាអ្នកចុះឈ្មោះតាមរយៈលេខដែលបានរាយនៅផ្នែកខាងក្រោមនៃទំព័រនេះ ដើម្បីស្វែងយល់អំពីសេវាកម្មទាំងនេះ។

សេវាកម្មផ្សេងទៀតដែលរ៉ាប់រងដោយ Medicare, MassHealth (Medicaid) ឬទីភ្នាក់ងាររដ្ឋ	ការចំណាយរបស់អ្នក
សេវាថែទាំនៅមន្ទីរពេទ្យមួយចំនួនដែលគ្របដណ្តប់នៅក្រៅ NaviCare	$0
ការកំណត់គោលដៅគ្រប់គ្រងករណី	$0
បន្ទប់ស្នាក់នៅនិងម្ហូបអាហារ	$0
សេវាជំនួយអន្តរកាល (TSS) សម្រាប់ជំងឺបណ្តាលមកពីការប្រើប្រាស់សារធាតុញៀន	$0

E. សេវាកម្មដែល NaviCare, Medicare និង MassHealth (Medicaid) មិនធានារ៉ាប់រង

នេះមិនមែនជាបញ្ជីពេញលេញទេ។ សូមទូរសព្ទទៅផ្នែកបម្រើសេវាអ្នកចុះឈ្មោះតាមរយៈលេខដែលបានរាយនៅផ្នែកខាងក្រោមនៃទំព័រនេះ ដើម្បីស្វែងយល់អំពីសេវាកម្មដែលមិនរាប់បញ្ចូលផ្សេងទៀត។

សេវាកម្មដែល NaviCare, Medicare និង MassHealth (Medicaid) មិនធានារ៉ាប់រង	
រាល់សេវាកម្ម នីតិវិធី ការព្យាបាល ឱសថ និងការផ្គត់ផ្គង់ដែលទាក់ទងនឹងការទាមទារសំណងរបស់កម្មករ	
នីតិវិធីលើកកំពស់ការជ្រើសរើសស្ម័គ្រចិត្តឬប្រកបដោយប្រសិទ្ធភាព	រួមបញ្ចូលទាំងនីតិវិធីសម្រកទម្ងន់។
សេវា/នីតិវិធី និងការផ្គត់ផ្គង់ឱសថសម្រាប់មុខងាររាងកាយ (រួមទាំងមន្ទីរពិសោធ និងអាហារបំប៉ន)	រួមបញ្ចូលឱសថជម្រើសបែបសន្តនិយមនិងព្យាបាលលក្ខណៈធម្មជាតិ។
ការវះកាត់កែវភ្នែកដោយកាំរស្មី និងការវះកាត់ LASIK	
សម្ភារៈផ្ទាល់ខ្លួននៅក្នុងបន្ទប់របស់អ្នកនៅមន្ទីរពេទ្យ ឬនៅមណ្ឌលថែទាំជំនាញ ដូចជា ទូរសព្ទ ឬទូរទស្សន៍	

F. សិទ្ធិរបស់អ្នកជាសមាជិកនៃគម្រោងនេះ

ក្នុងនាមជាសមាជិករបស់ NaviCare អ្នកមានសិទ្ធិជាក់លាក់មួយចំនួន។ អ្នកអាចប្រើសិទ្ធិទាំងនេះដោយមិនមានការរងទណ្ឌកម្ម។ អ្នកក៏អាចប្រើសិទ្ធិទាំងនេះដោយមិនបាត់បង់សេវាកម្មថែទាំសុខភាពរបស់អ្នកផងដែរ។ យើងនឹងប្រាប់អ្នកអំពីសិទ្ធិរបស់អ្នកយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។ សម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិរបស់អ្នក សូមអាន *សៀវភៅណែនាំសមាជិក*។ សិទ្ធិរបស់អ្នករួមមានជាអាទិ៍ដូចខាងក្រោម៖

- អ្នកមានសិទ្ធិទទួលបានការគោរព យុត្តិធម៌ និងសេចក្តីថ្លៃថ្នូរ។ នេះរួមបញ្ចូលទាំងសិទ្ធិដើម្បី៖
    - ទទួលបានសេវាដែលមានការធានារ៉ាប់រងដោយគ្មានការព្រួយបារម្ភអំពីស្ថានភាពវេជ្ជសាស្ត្រ ស្ថានភាពសុខភាព ការទទួលសេវាសុខភាព បទពិសោធទាមទារសំណង ប្រវត្តិវេជ្ជសាស្ត្រ ពិការភាព (រួមទាំងការចុះខ្សោយអាកប្បកិរិយា) ស្ថានភាពអាពាហ៍ពិពាហ៍ អាយុ ភេទ ទំនោរផ្លូវភេទ ដើមកំណើតជាតិ ពូជសាសន៍ ពណ៌សម្បុរ សាសនា ជំនឿ ឬជំនួយសាធារណៈ
    - ទទួលបានព័ត៌មានជាភាសា និងទម្រង់ផ្សេងទៀត (ឧទាហរណ៍ អក្សរពុម្ពធំ អក្សរស្មាបសម្រាប់ជនពិការភ្នែក ឬជាសំឡេង) ដោយឥតគិតថ្លៃ
    - ត្រូវរួចផុតពីទម្រង់នៃការរឹតបន្តឹងរាងកាយ ឬភាពឯកោ
- អ្នកមានសិទ្ធិក្នុងការទទួលបានព័ត៌មានអំពីការថែទាំសុខភាពរបស់អ្នក។ នេះរួមបញ្ចូលទាំងព័ត៌មានអំពីការព្យាបាលនិងជម្រើសនៃការព្យាបាលរបស់អ្នក។ ព័ត៌មាននេះគួរតែមានជាភាសា និងទម្រង់ដែលអ្នកអាចយល់បាន។ នេះរួមបញ្ចូលទាំងសិទ្ធិក្នុងការទទួលបានព័ត៌មាននៅលើ៖
    - ការពិពណ៌នាអំពីសេវាកម្មដែលយើងគ្របដណ្តប់
    - វិធីទទួលបានសេវាកម្ម
    - តម្លៃដែលអ្នកត្រូវចំណាយលើសេវាកម្ម
    - ឈ្មោះអ្នកផ្តល់ការថែទាំសុខភាព និងអ្នកស្វែងរកសេវាកម្ម
- អ្នកមានសិទ្ធិក្នុងការសម្រេចចិត្តអំពីការថែទាំរបស់អ្នក រួមទាំងការបដិសេធការព្យាបាល។ នេះរួមបញ្ចូលទាំងសិទ្ធិដើម្បី៖
    - ជ្រើសរើសអ្នកផ្តល់សេវាថែទាំបឋម (PCP) និងផ្លាស់ប្តូរ PCP របស់អ្នកនៅពេលណាមួយក៏បាននៅក្នុងអំឡុងឆ្នាំ
    - ជ្រើសរើសអ្នកសម្របសម្រួលសេវាកម្មគាំទ្រមនុស្សចាស់ (GSSC)
    - ជួបជាមួយអ្នកផ្តល់សេវាថែទាំសុខភាពស្ត្រីដោយគ្មានការបញ្ជូនបន្ត
    - ទទួលបានសេវាកម្ម និងឱសថដែលមានការធានារ៉ាប់រងរបស់អ្នកយ៉ាងឆាប់រហ័ស
    - ដឹងអំពីជម្រើសនៃការព្យាបាលទាំងអស់ មិនថាវាមានតម្លៃប៉ុន្មាន ឬថាតើវាត្រូវបានរ៉ាប់រងដែរឬទេ
    - បដិសេធការព្យាបាល ទោះបីជាអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកផ្តល់ដំបូន្មានជំទាស់នឹងរឿងនេះក៏ដោយ
    - ឈប់ប្រើថ្នាំសូម្បីតែអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកផ្តល់ដំបូន្មានជំទាស់នឹងរឿងនេះក៏ដោយ
    - សួររកគំនិតទីពីរ។ NaviCare នឹងបង់លើការចំណាយសម្រាប់ការទៅជួបពិនិត្យលើកទីពីររបស់អ្នក
    - ធ្វើឱ្យគេដឹងអំពីបំណងប្រាថ្នាសុខភាពរបស់អ្នកក្នុងសេចក្តីបង្គាប់បញ្ជាទុកជាមុន
- អ្នកមានសិទ្ធិក្នុងការទទួលបានការថែទាំទាន់ពេលវេលា ដែលមិនមានឧបសគ្គក្នុងការទំនាក់ទំនង ឬឧបសគ្គខាងរាងកាយ។ នេះរួមបញ្ចូលទាំងសិទ្ធិដើម្បី៖

- ទទួលបានការថែទាំវេជ្ជសាស្ត្រទាន់ពេលវេលាសម្រាប់សេវាកម្មដែលបានរ៉ាប់រងក្នុងរយៈពេលដែលបានពិពណ៌នានៅក្នុង *សៀវភៅណែនាំសមាជិក* និងដាក់បណ្តឹងឧទ្ធរណ៍ប្រសិនបើអ្នកមិនទទួលបានការថែទាំរបស់អ្នកក្នុងរយៈពេលទាំងនោះ។
- ចូល និងចេញពីការិយាល័យរបស់អ្នកផ្តល់សេវាថែទាំសុខភាព។ នេះមានន័យថាការចូលប្រើដោយគ្មានឧបសគ្គសម្រាប់ជនពិការ ស្របតាមច្បាប់ជនពិការអាមេរិក
- មានអ្នកបកប្រែផ្ទាល់មាត់ដើម្បីជួយក្នុងការប្រាស្រ័យទាក់ទងជាមួយវេជ្ជបណ្ឌិតរបស់អ្នក អ្នកផ្តល់សេវាផ្សេងទៀត និងគម្រោងសុខភាពរបស់អ្នក។ សូមទូរសព្ទទៅលេខ 1-877-700-6996 (TTY 711) ប្រសិនបើអ្នកត្រូវការជំនួយជាមួយសេវាកម្មនេះ។
- ឱ្យ *សៀវភៅណែនាំសមាជិក* និងឯកសារដែលបានបោះពុម្ពពី NaviCare របស់អ្នកបកប្រែទៅជាភាសានិយមប្រើរបស់អ្នក និង/ឬឱ្យអានឯកសារទាំងនេះឱ្យអ្នកឮ ប្រសិនបើអ្នកមានបញ្ហាក្នុងការមើល ឬអាន។ សេវាបកប្រែផ្ទាល់មាត់នឹងអាចរកបានតាមការស្នើសុំ និងដោយឥតគិតថ្លៃ។
- ត្រូវរួចផុតពីទម្រង់នៃការរឹតបន្តឹងរាងកាយ ឬភាពឯកោដែលនឹងត្រូវបានប្រើជាមធ្យោបាយនៃការបង្ខិតបង្ខំ ការជំរុញ វិន័យ ភាពងាយស្រួល ឬការសងសឹកនោះទេ។

- **អ្នកមានសិទ្ធិក្នុងការស្វែងរកការថែទាំក្នុងគ្រាអាសន្ន និងបន្ទាន់ នៅពេលដែលអ្នកត្រូវការវា។ នេះមានន័យថាអ្នកមានសិទ្ធិក្នុងការ៖**
  - ទទួលបានសេវាសង្គ្រោះបន្ទាន់ដោយគ្មានការអនុញ្ញាតជាមុនក្នុងគ្រាអាសន្ន
  - ជួបជាមួយអ្នកផ្តល់សេវាថែទាំបន្ទាន់ ឬក្នុងគ្រាអាសន្នក្រៅបណ្តាញ នៅពេលចាំបាច់
- **អ្នកមានសិទ្ធិទទួលបានការរក្សាការសម្ងាត់ និងឯកជនភាព។ នេះរួមបញ្ចូលទាំងសិទ្ធិដើម្បី៖**
  - ស្នើសុំច្បាប់ចម្លងនៃកំណត់ត្រាវេជ្ជសាស្ត្ររបស់អ្នកតាមរបៀបដែលអ្នកអាចយល់បាននិងស្នើសុំកែប្រែឬផ្លាស់ប្តូរកំណត់ហេតុរបស់អ្នក
  - រក្សាព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នកជាឯកជន
  - មានភាពឯកជនក្នុងអំឡុងពេលព្យាបាល
- **អ្នកមានសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងអំពីសេវាកម្ម ឬការថែទាំដែលមានការធានារ៉ាប់រងរបស់អ្នក។ នេះរួមបញ្ចូលទាំងសិទ្ធិដើម្បី៖**
  - ដាក់ពាក្យបណ្តឹងតវ៉ា ឬបណ្តឹងសាទុក្ខប្រឆាំងនឹងយើង ឬអ្នកផ្តល់សេវារបស់យើង
  - ដាក់ពាក្យបណ្តឹងជាមួយ MassHealth (Medicaid) ដោយទូរសព្ទទៅសេវាបម្រើអតិថិជន MassHealth (Medicaid) តាមរយៈលេខ 1-800-841-2900។ អ្នកប្រើប្រាស់ TTY គួរទូរសព្ទទៅកាន់លេខ 711។ គេហទំព័រ NaviCare fallonhealth.org/navicare មានព័ត៌មានអំពីការដាក់បណ្តឹងឧទ្ធរណ៍។
  - ស្នើសុំការពិនិត្យឡើងវិញផ្នែកវេជ្ជសាស្ត្រឯករាជ្យនៃសេវាកម្ម ឬទំនិញ MassHealth (Medicaid) ដែលមានលក្ខណៈវេជ្ជសាស្ត្រ
  - ប្តឹងឧទ្ធរណ៍លើការសម្រេចចិត្តជាក់លាក់ដែលធ្វើឡើងដោយ MassHealth (Medicaid) ឬអ្នកផ្តល់សេវារបស់យើង
  - ស្នើសុំសវនាការថ្នាក់រដ្ឋ
  - ទទួលបានហេតុផលលម្អិតអំពីមូលហេតុដែលសេវាកម្មត្រូវបានបដិសេធ

សម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិរបស់អ្នក អ្នកអាចអាន *សៀវភៅណែនាំសមាជិក*។ ប្រសិនបើអ្នកមានសំណួរ អ្នកអាចទូរសព្ទទៅផ្នែកបម្រើសេវាអ្នកចុះឈ្មោះរបស់ NaviCare តាមរយៈលេខដែលបានរាយនៅផ្នែកខាងក្រោមនៃទំព័រនេះ។

អ្នកក៏អាចទូរសព្ទទៅការិយាល័យមន្ត្រីបណ្តឹងសាធារណៈតាមរយៈលេខ 1-855-781-9898 (ឬប្រើ MassRelay តាមរយៈលេខ 711 ដើម្បីទូរសព្ទទៅលេខ 1-855-781-9898 ឬទូរសព្ទជាវីដេអូ (VP) ទៅលេខ 339-224-6831)។

G. របៀបនៃការដាក់ពាក្យបណ្តឹងឬប្តឹងឧទ្ធរណ៍លើការបដិសេធសេវាកម្ម

ប្រសិនបើអ្នកមានបណ្តឹងតវ៉ា ឬគិតថា NaviCare គួរតែធានារ៉ាប់រងលើអ្វីដែលយើងបានបដិសេធ សូមទូរសព្ទទៅផ្នែកបម្រើសេវាអ្នកចុះឈ្មោះតាមរយៈលេខដែលបានរាយនៅផ្នែកខាងក្រោមនៃទំព័រនេះ។ > អ្នកអាចប្តឹងឧទ្ធរណ៍លើការសម្រេចចិត្តរបស់យើងបាន។

សម្រាប់សំណួរអំពីបណ្តឹងតវ៉ា និងបណ្តឹងឧទ្ធរណ៍ អ្នកអាចអានជំពូកទី 9 នៃ *សៀវភៅណែនាំសមាជិក*។ អ្នកក៏អាចទូរសព្ទទៅផ្នែកបម្រើសេវាអ្នកចុះឈ្មោះរបស់ NaviCare តាមរយៈលេខដែលបានរាយនៅផ្នែកខាងក្រោមនៃទំព័រនេះ។

H. តើអ្នកត្រូវធ្វើអ្វីប្រសិនបើអ្នកសង្ស័យថាមានការក្លែងបន្លំ

អ្នកជំនាញនិងអង្គការថែទាំសុខភាពភាគច្រើនដែលផ្តល់សេវាគឺមានភាពស្មោះត្រង់។ ជាអកុសល ប្រហែលជាមានអ្នកខ្លះដែលមិនស្មោះត្រង់។ ប្រសិនបើអ្នកគិតថាគ្រូពេទ្យ មន្ទីរពេទ្យឬឱសថស្ថានផ្សេងទៀតកំពុងធ្វើអ្វីដែលខុស សូមទាក់ទងមកយើងខ្ញុំ។

- សូមទូរសព្ទទៅសេវាបម្រើអ្នកចុះឈ្មោះរបស់ NaviCare។ លេខទូរសព្ទត្រូវបានរាយនៅផ្នែកខាងក្រោមនៃទំព័រនេះ។
- ឬទូរសព្ទទៅផ្នែកសេវាបម្រើអតិថិជនរបស់ MassHealth (Medicaid) តាមរយៈលេខ 1-800-841-2900។ អ្នកប្រើប្រាស់ TTY អាចទូរសព្ទទៅលេខ 711។
- ឬទូរសព្ទទៅ Medicare តាមលេខ 1-800-MEDICARE (1-800-633-4227)។ អ្នកប្រើប្រាស់ TTY អាចទូរស័ព្ទទៅកាន់លេខ 1-877-486-2048។ អ្នកអាចទូរសព្ទទៅលេខទាំងនេះដោយឥតគិតថ្លៃ។

I. អ្វីដែលត្រូវធ្វើ ប្រសិនបើអ្នកចង់បានជំនួយឯករាជ្យជាមួយពាក្យបណ្តឹង ឬកង្វល់

កម្មវិធីមន្ត្រីបណ្តឹងសាធារណៈរបស់ខ្ញុំ គឺជាកម្មវិធីឯករាជ្យមួយដែលអាចជួយអ្នកបាន ប្រសិនបើអ្នកមានសំណួរ ការព្រួយបារម្ភ ឬបញ្ហាដែលទាក់ទងនឹង SCO។ អ្នកអាចទាក់ទងកម្មវិធីមន្ត្រីបណ្តឹងសាធារណៈរបស់ខ្ញុំដើម្បីទទួលបានព័ត៌មាន ឬជំនួយ។ សេវាកម្មរបស់កម្មវិធីមន្ត្រីបណ្តឹងសាធារណៈរបស់ខ្ញុំ គឺមិនគិតថ្លៃទេ។ បុគ្គលិកនៃកម្មវិធីមន្ត្រីបណ្តឹងសាធារណៈរបស់ខ្ញុំ៖

- អាចឆ្លើយសំណួររបស់អ្នក ឬបញ្ជូនអ្នកទៅកាន់កន្លែងត្រឹមត្រូវ ដើម្បីស្វែងរកអ្វីដែលអ្នកត្រូវការ។
- អាចជួយអ្នកដោះស្រាយបញ្ហា ឬកង្វល់ជាមួយគម្រោង SCO ឬ SCO, NaviCare របស់អ្នក។ បុគ្គលិកនៃកម្មវិធីមន្ត្រីបណ្តឹងសាធារណៈរបស់ខ្ញុំនឹងស្តាប់ ស៊ើបអង្កេតបញ្ហា និងពិភាក្សាអំពីជម្រើសជាមួយអ្នកដើម្បីជួយដោះស្រាយបញ្ហា។
- ជួយជាមួយបណ្តឹងឧទ្ធរណ៍។ បណ្តឹងឧទ្ធរណ៍គឺជាវិធីផ្លូវការមួយក្នុងការស្នើសុំគម្រោង SCO របស់អ្នក MassHealth (Medicaid) ឬ Medicare ដើម្បីពិនិត្យឡើងវិញនូវការសម្រេចចិត្តអំពីសេវាកម្មរបស់អ្នក។ បុគ្គលិករបស់កម្មវិធីមន្ត្រីបណ្តឹងសាធារណៈរបស់ខ្ញុំអាចនិយាយជាមួយអ្នកអំពីរបៀបប្តឹងឧទ្ធរណ៍ និងអ្វីដែលត្រូវរំពឹងទុកក្នុងអំឡុងពេលដំណើរការបណ្តឹងឧទ្ធរណ៍។

អ្នកអាចទូរសព្ទ សរសេរ ឬទៅជួបកម្មវិធីមន្ត្រីបណ្តឹងសាធារណៈរបស់ខ្ញុំនៅការិយាល័យរបស់កម្មវិធី។

- សូមទូរសព្ទទៅលេខ 1-855-781-9898 ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង 9 ព្រឹក ដល់ម៉ោង 4 ល្ងាច។
    - ប្រើ 7-1-1 ដើម្បីទូរសព្ទទៅលេខ 1-855-781-9898។ លេខនេះគឺសម្រាប់មនុស្សថ្លង់ ស្តាប់មិនបាន ឬនិយាយមិនកើត។

  - ប្រើទូរសព្ទមានប្រព័ន្ធវីដេអូ (VP) 339-224-6831។ លេខនេះគឺសម្រាប់មនុស្សថ្លង់ ឬពិបាកស្តាប់។
- អ៊ីមែល info@myombudsman.org
- សរសេរទៅកាន់ ឬទៅជួបការិយាល័យកម្មវិធីមន្ត្រីបណ្តឹងសាធារណៈរបស់ខ្ញុំនៅអាសយដ្ឋាន 25 Kingston Street, 4th floor, Boston, MA 02111
  - សូមមើលគេហទំព័រ My Ombudsman ឬទាក់ទងពួកគេដោយផ្ទាល់សម្រាប់ព័ត៌មានថ្មីៗអំពីទីតាំង និងម៉ោងដើរ។
- ចូលមើល My Ombudsman តាមអនឡាញនៅ www.myombudsman.org

ប្រសិនបើអ្នកមានសំណួរទូទៅ ឬសំណួរអំពីគម្រោង សេវា តំបន់សេវា ការចេញវិក្កយបត្រ ឬបណ្ណ ID សម្គាល់សមាជិករបស់យើង សូមហៅទូរសព្ទទៅសេវាកម្មចុះឈ្មោះរបស់ NaviCare៖

1-877-700-6996

ការហៅទៅកាន់លេខនេះគឺឥតគិតថ្លៃ។ អ្នកតំណាងអាចរកបាន

8 ព្រឹក ដល់ 8 យប់ ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ (7 ថ្ងៃក្នុងមួយសប្តាហ៍ ពីថ្ងៃទី 1 ខែតុលា ដល់ថ្ងៃទី 31 ខែមីនា)។

ក្នុងអំឡុងពេលផ្សេងទៀតទាំងអស់ អ្នកហៅទូរស័ព្ទចូលអាចថតទុកសារជាសម្លេង។

សារនឹងត្រូវបានហៅត្រឡប់មកវិញនៅថ្ងៃធ្វើការបន្ទាប់។

សេវាកម្មអ្នកចុះឈ្មោះក៏មានសេវាកម្មអ្នកបកប្រែភាសាផ្ទាល់មាត់ដោយឥតគិតថ្លៃផងដែរសម្រាប់សមាជិកដែលត្រូវការសេវាកម្មបកប្រែផ្ទាល់មាត់។

TTY 711

លេខនេះត្រូវការឧបករណ៍ទូរស័ព្ទពិសេស ហើយសម្រាប់តែអ្នកដែលពិបាកស្តាប់ ឬនិយាយប៉ុណ្ណោះ។
ការហៅទៅកាន់លេខទូរស័ព្ទនេះគឺឥតគិតថ្លៃនិងអាចរកបាន 24/7 ។

ប្រសិនបើអ្នកមានសំណួរអំពីសុខភាពរបស់អ្នក៖

- សូមទូរសព្ទទៅអ្នកផ្តល់សេវាថែទាំបឋម (PCP) របស់អ្នក។ អនុវត្តតាមការណែនាំរបស់ PCP របស់អ្នកសម្រាប់ការទទួលបានការថែទាំនៅពេលការិយាល័យបិទ។
- ប្រសិនបើការិយាល័យ PCP របស់អ្នកបិទ អ្នកក៏អាចទូរសព្ទទៅ Care Connect ផងដែរ។ គិលានុបដ្ឋាយិកានឹងស្តាប់បញ្ហារបស់អ្នក ហើយប្រាប់អ្នកពីរបៀបទទួលបានការថែទាំ។ (*ឧទាហរណ៍៖* ការថែទាំបន្ទាន់ បន្ទប់សង្គ្រោះបន្ទាន់។)

លេខសម្រាប់ Care Connect គឺ៖

1-800-609-6175

ការហៅទៅកាន់លេខទូរស័ព្ទនេះគឺឥតគិតថ្លៃនិងអាចរកបាន 24/7 ។ NaviCare
ក៏មានសេវាកម្មអ្នកបកប្រែភាសាផ្ទាល់មាត់ដោយឥតគិតថ្លៃផងដែរសម្រាប់សមាជិកដែលត្រូវការសេវាកម្មបកប្រែផ្ទាល់មាត់។

TTY: 1-800-848-0160

ការហៅទៅកាន់លេខទូរស័ព្ទនេះគឺឥតគិតថ្លៃនិងអាចរកបាន 24/7 ។

ប្រសិនបើអ្នកត្រូវការការថែទាំសុខភាពអាកប្បកិរិយាភ្លាមៗ សូមទូរសព្ទទៅកម្មវិធីសេវាសង្គ្រោះបន្ទាន់/បណ្តាញទូរសព្ទចល័តសម្រាប់អន្តរាគមន៍វិបត្តិ៖

1-877-382-1609

ការហៅទៅកាន់លេខទូរស័ព្ទនេះគឺឥតគិតថ្លៃនិងអាចរកបាន 24/7 ។ NaviCare
ក៏មានសេវាកម្មអ្នកបកប្រែភាសាផ្ទាល់មាត់ដោយឥតគិតថ្លៃផងដែរសម្រាប់សមាជិកដែលត្រូវការសេវាកម្មបកប្រែផ្ទាល់មាត់។

TTY: 711

ការហៅទៅកាន់លេខទូរស័ព្ទនេះគឺឥតគិតថ្លៃនិងអាចរកបាន 24/7 ។

fallonhealth